# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*បើយើងអ្នកតស៊ូហ្នឹង ចង់រស់ ទាល់តែយើងដាច់ខាតដឹងថាត្រូវជម្លៀសចេញឲ្យអស់។ ហើយនៅតែអ្នកធ្វើបដិវត្តន៍ហ្នឹងចូលទៅវាស្រួលជាង ស្រួលគ្រប់គ្រង។ អាហ្នឹង បងប្អូននៅខាងក្រោម គេនិយាយគ្រប់ៗគ្នាអ៊ីចឹង។ អាហ្នឹង ខ្ញុំស្តាប់ហ្នឹង ហើយតែផែនការពីលើ វាឃើញសមស្របគ្នាអ៊ឹងចឹងដែរ។*

- **សាក្សី រ៉ចាម តុន**

**ផ្តល់សក្ខីកម្មស្តីពីការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញ**

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបញ្ចប់ការផ្តល់សក្ខីកម្មរបស់សាក្សីជំនាញ លោកសាស្ត្រាចារ្យ **ដេវីដ ឆេនដ៍ល័រ** *(Prof. David Chandler TCE11)*។ ក្រៅពីការផ្តល់សក្ខីកម្មស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា លោកសាស្ត្រាចារ្យ **ដេវីដ ឆេនដ៍ល័រ** បានឆ្លើយតបទៅនឹងសំណួរជាច្រើនប្រកបដោយភាពច្បាស់លាស់ និងពិបាកឆ្លើយ ស្តីពីវិធីសាស្ត្រស្រាវជ្រាវ និងប្រភពនៃការស្វែងរកព័ត៌មានរបស់គាត់។ ជនជាប់ចោទលោក **នួន ជា** បានជ្រើសរើសមិននៅស្ងៀមស្ងាត់ ដើម្បីលើកឡើងនូវសំណួរចំនួនពីរទៅកាន់លោកសាស្ត្រាចារ្យ **ដេវីដ ឆេនដ៍ល័រ** ។

សាក្សីទីពីរគឺលោក **រ៉ចាម តុន** បានផ្តល់សក្ខីកម្មថា គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយ **ប៉ុល ពត** និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ចាប់ពីចុងឆ្នាំ១៩៦៧។ សាក្សី បានផ្តល់សក្ខីកម្មយ៉ាងលម្អិតទាក់ទងទៅនឹងរចនាសម្ព័ន្ធ និងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា រួមបញ្ចូលទាំងសកម្មភាពរបស់មេដឹកនាំក្នុងអំឡុងពេលនៃ “ការរំដោះ” ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥។

សាស្ត្រាចារ្យ **ឆេនដ៍ល័រ** និងសាក្សី **រ៉ចាម តុន** បានមកផ្តល់សក្ខីកម្មរបស់ពួកគាត់យ៉ាងចំចំណុចដែលធ្វើឲ្យនីតិវិធីសវនាការក្នុងសប្តាហ៍នេះដំណើរការលឿន និងទទួលបានព័ត៌មានច្រើន។

## ផ្នែកទី ២៖ ការសង្ខេបសក្ខីកម្មរបស់សាក្សី

លោកសាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានផ្តល់សក្ខីកម្មលើប្រធានបទជាច្រើនរួមមាន៖ ប្រភពដើម រចនាសម្ព័ន្ធ គោលនយោបាយ និងការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់ក៏បានផ្តល់សក្ខីកម្មយ៉ាងលម្អិតអំពីវិធីសាស្ត្រនៃការស្រាវជ្រាវនេះ និងឯកសារយោងដទៃទៀត ដែលគាត់បានប្រើប្រាស់នៅក្នុងការសិក្សារបស់គាត់។ សាក្សីទីពីរ គឺលោក **វ៉ាចាម តុន** បានផ្តល់សក្ខីកម្មពីព័ត៌មានដែលគាត់បានប្រមូល នៅខណៈដែលគាត់ធ្វើជាអង្គរក្ស និងនីរសាររបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងក្រោយ "ការរំដោះ" ទីក្រុងភ្នំពេញ ដែលគាត់មានតួនាទីជាប្រធានផ្នែករដ្ឋបាលការិយាល័យ ប-៥។

### ក. សក្ខីកម្មរបស់សាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ

ក្រុមមេធាវីការពារក្តីបានសួរសាស្ត្រាចារ្យ **ដេវីដ ឆេនដ៍ល័រ** ចំពោះប្រភពព័ត៌មានរបស់គាត់ និងបានស្នើសុំឲ្យមានការបកស្រាយលើសេចក្តីថ្លែងការណ៍ ដែលគាត់បានធ្វើនៅក្នុងការបោះពុម្ពផ្សាយស្នាដៃរបស់គាត់។ ជាពិសេសទៅទៀត ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** បានសួរសំណួរទៅកាន់គាត់នូវអ្វីដែលបានលេចឡើង នូវភាពមិនស៊ីចង្វាក់គ្នាក្នុងការចុះផ្សាយស្នាដៃរបស់គាត់។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** បានសួរសាស្ត្រាចារ្យ **ឆេនដ៍ល័រ** អំពីភស្តុតាងដែលផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា លើសកម្មភាពជាក់ស្តែង ដែលបានអនុវត្តចំពោះកម្មាភិបាលថ្នាក់ក្រោម។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** ក៏បានឆ្លើយតបទៅនឹងសំណួររបស់ជនជាប់ចោទ **នួន ជា** លើបញ្ហាជម្លោះរវាងវៀតណាម និងគណបក្សប្រជាជនកម្ពុជា និងការបង្កើតបក្សកុម្មុយនីស្តកម្ពុជា។ ក្រុមមេធាវីការពារឲ្យជនជាប់ចោទ **ខៀវ សំផន** បានស្វែងរកការបកស្រាយដែលពាក់ព័ន្ធទៅនឹងប្រភពភស្តុតាង ដែលបង្ហាញពីការចូលរួមរបស់ជនជាប់ចោទ **ខៀវ សំផន** ក្នុងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា។

#### *ក.១. រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា*

យោងតាមសាស្ត្រាចារ្យ **ឆេនដ៍ល័រ** បក្សកុម្មុយនីស្តកម្ពុជាផ្ទាល់ គឺមានអំណាចច្រើនជាងអង្គការដទៃទៀត ដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ។ សកម្មភាពរបស់បក្ស និងរដ្ឋាភិបាល គឺជាន់គ្នា ពីព្រោះសុទ្ធតែសមាជិកគណបក្សធ្វើការ និងកាន់តំណែងខ្ពស់ក្នុងជួររដ្ឋាភិបាល។ នៅពេលដែលគណបក្ស និងរដ្ឋាភិបាល មានការបែងចែកផ្សេងគ្នា និងខុសគ្នានៅលើក្រដាស តែការពិតនោះ គឺគ្មានបែងចែករវាងស្ថាប័នទាំងពីរនេះទេ។

សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានកត់សម្គាល់ថា រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រមូលផ្តុំជារាងពីរ៉ាមិត ដែលមានស្ថាប័នមានអំណាចជាងគេនៅកំពូល គឺគណៈអចិន្ត្រៃយ៍។ សមាជិកទាំងអស់មានប្រាំពីរ ឬប្រាំបីនាក់នៃគណៈអចិន្ត្រៃយ៍ គឺជាសមាជិកនៃគណៈមជ្ឈិម ដែលមានសមាជិកចំនួន២០នាក់។ យ៉ាងណាមិញ យោងតាមសាស្ត្រាចារ្យ **ឆេនដ៍ល័រ** វាជារឿងធម្មតាទេសម្រាប់មេដឹកនាំមានអំណាចខ្លាំង និងមានសិទ្ធិក្នុងការអនុវត្តន៍ ជាជាងការបង្ហាញនៅក្នុងតារាងអង្គការបក្ស។ លើសពីទៅនេះទៀត សាស្ត្រាចារ្យ **ឆេនដ៍ល័រ**

បានបញ្ជាក់ថា របបកម្ពុជាប្រជាធិបតេយ្យ គឺជា "ថ្នាក់ដឹកនាំបែបសមូហភាព" ដែលសមាជិកត្រូវតែដឹងពីអ្វីដែលកំពុងបានកើតឡើង ហើយជឿជាក់ថា ពួកគេបានទទួលព័ត៌មានទាំងនោះ។ គណៈមជ្ឈិម បានផ្តល់គណៈអចិន្ត្រៃយ៍នូវព័ត៌មាន និងសំណើនានា ក៏ប៉ុន្តែសមាជិកគណៈអចិន្ត្រៃយ៍ផ្ទាល់ មិនមានសិទ្ធិអំណាចក្នុងការធ្វើសំណើសុំទៅគណៈមជ្ឈិមទេ លុះត្រាតែសមាជិករបស់គេធ្វើកិច្ចពិភាក្សាលើបញ្ហានោះសិន និងលេខាបក្ស **ប៉ុល ពត** ប្រកាសសម្រេច។ ដូច្នេះ សាស្ត្រាចារ្យ **ឆេនដ័ល័រ** បានពន្យល់ថា ខណៈពេលដែលការដឹកនាំជាសមូហភាព **ប៉ុល ពត** ជាអ្នកនិយាយ និងសម្រេចចុងក្រោយគេ។ សាក្សីបានបន្ថែមទៀតថា ការណែនាំដែលគណៈមជ្ឈិមបានទទួលពីគណៈអចិន្ត្រៃយ៍ជាការសម្រេចចុងក្រោយ។

សាក្សីបានថ្លែងថា "អង្គការ" គឺសំដៅទៅលើស្ថាប័ន។ សមាជិកក្នុងបក្ស មិនបានសំដៅទៅលើ **ប៉ុល ពត**[1] ថាជា "អង្គការ" នោះទេ។ យ៉ាងណាមិញ នៅទីជនបទ ប្រជាពលរដ្ឋបានគិតថា "អង្គការ" គឺសំដៅលើមនុស្សជាក់លាក់ម្នាក់ ពីព្រោះពួកគេ មិនដែលមានបទពិសោធន៍ពីការដឹកនាំបែបសមូហភាពពីមុនទេ។ ច្រើនជាងនេះទៅទៀត សាស្ត្រាចារ្យ **ឆេនដ័ល័រ** បាននិយាយថា នៅក្នុងទសវត្សរ៍ទី៩០ ពេលខ្លះ **ប៉ុល ពត** បានធ្វើការសម្រេចចិត្តដោយខ្លួនគាត់ផ្ទាល់។ ក៏ប៉ុន្តែ មិនមានភស្តុតាងណាមួយបញ្ជាក់អំពីភាពម្ចាស់ការលើសម្រេចនេះក្នុងអំឡុងពេលនៃរបបនោះឡើយ។ សាស្ត្រាចារ្យ **ឆេនដ័ល័រ** ក៏បានធ្វើការបង្ហើបពីការសម្ងាត់ដែលរបបនោះធ្វើប្រតិបត្តិការរបស់ខ្លួនៈ កិច្ចការងារជាច្រើនរបស់រដ្ឋាភិបាល ត្រូវបានលាក់ការណ៍ ហើយសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាត្រូវបានរក្សាការសម្ងាត់ទាំងនោះ។

### *ក.២. ការទម្លាក់គ្រាប់បែករបស់អាមេរិកាំង*

សាស្ត្រចារ្យ **ឆេនដ័ល័រ** បានរៀបរាប់អំពីការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិកនៅកម្ពុជា "ជាសម័យកាលដ៏ខ្មៅងងឹត ដែលប្រព្រឹត្តដោយបរទេស"។ ការទម្លាក់គ្រាប់បែកចាប់ផ្តើមនៅដើមឆ្នាំ១៩៦៧ ប៉ុន្តែកាន់តែខ្លាំងឡើងនៅឆ្នាំ១៩៧៣ ជាឆ្នាំតែមួយដែលសហរដ្ឋអាមេរិក បានចុះហត្ថលេខាលើការបញ្ឈប់ការផ្ទុះអាវុធជាមួយប្រទេសវៀតណាម។ សាស្ត្រចារ្យ **ឆេនដ័ល័រ** បាននិយាយថាៈ

> *កម្ពុជា គឺមានសង្គ្រាមតែក្នុងស្រុកទេ។ ដូច្នេះហើយ គឺបទឈប់បាញ់គ្នានោះ គឺមិនទាក់ទងនឹងកម្ពុជាទេ។ ហើយនេះជាចំនុចដែលគួរឲ្យចាប់អារម្មណ៍ ហើយទាក់ទងទៅនឹងវៀតណាម និងសហរដ្ឋអាមេរិក ហើយឆ្នាំ១៩៧៣ហ្នឹង គឺជាឆ្នាំដែលគេទម្លាក់គ្រាប់បែកច្រើនជាងគេ នៅពេលដែលៗ វាមានការទាក់ទងទៅនឹងសង្គ្រាមនៅវៀតណាម។*

ផ្អែកទៅតាមសាក្សី "សង្គ្រាមចិត្តសាស្ត្រតែមួយគត់របស់ខ្មែរក្រហម" គឺរៀបរាប់អំពីការទម្លាក់គ្រាប់បែកថាជា "រដ្ឋាភិបាលក្បត់ប្រជាជន" ហើយបានប្រាប់ប្រជាជនថា ពួកគេនឹងអាចទទួលរងនូវការទម្លាក់គ្រាប់បែកពីអាមេរិក ដែលនឹង "សំដៅមករកពួកគេដោយផ្ទាល់" ពទីក្រុងភ្នំពេញ។ នៅក្នុងទស្សនៈរបស់សាក្សី ការទម្លាក់គ្រាប់បែកនាំឲ្យប្រជាជនភៀសខ្លួនពីភ្នំពេញ ហើយចូលរួមជាមួយខ្មែរក្រហម។ យ៉ាងណាមិញ សាក្សីបានទទួលស្គាល់ថា ចំនួននៃការជ្រើសរើសអ្នកដែលបានចូលរួមខ្មែរក្រហម បានមកដោយសារតែការទម្លាក់

គ្រាប់បែក គឺមិនបានកត់ត្រាទុក និងមិនមានភាពជាក់លាក់នោះឡើយ។ ចំនួនយោធាខ្មែរក្រហមដែលបានរបួសស្លាប់ដោយសារការទម្លាក់គ្រាប់បែក គឺមិនបានដឹងទេ ក៏ប៉ុន្តែ គាត់បង្ហាញថា កាលៈទេសៈទាំងនេះបានពន្យារពេល "ការរំដោះ" ទីក្រុងភ្នំពេញអស់រយៈ ពេលពីរឆ្នាំ។ គាត់បានសន្និដ្ឋានទៀតថា ផលវិបាកជាចម្បងនៃការទម្លាក់គ្រាប់នេះ នាំឲ្យមានការហូរចូលប្រជាជនជាច្រើនពីទីជនបទទៅកាន់ទីក្រុងភ្នំពេញ។ គាត់បានរំឭកថា នៅខែមេសា ឆ្នាំ១៩៧៥ ចំនួនប្រជាជននៅទីក្រុងភ្នំពេញមានប្រមាណពីពីរលានទៅពីរលានកន្លះ។ ទាំងនេះជាចំនួនប្រជានជនខុសគ្នាទាំងស្រុងពីឆ្នាំ១៩៧០ ទៅឆ្នាំ១៩៧១ ដែលមានចំនួនត្រឹមតែកន្លះលាននាក់ប៉ុណ្ណោះ។ គាត់បានសន្មតថា ផ្នែកមួយនៃការបំលាស់ទីចូលទៅក្នុងទីក្រុងភ្នំពេញ នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ គឺជាការស្វែងរកការជ្រកកោនក្នុងរាជធានីដើម្បីរត់គេចពីការទម្លាក់។ សាស្ត្រាចារ្យ **ឆេនដ័លរ័** បានបង្ហើបថា ការបំលាស់ទីប្រជាជនបានកើនឡើងនៅក្នុងទីក្រុងភ្នំពេញ បានបណ្តាលឲ្យលក្ខខណ្ឌរស់នៅទីក្រុងកាន់តែពិបាក ប្រឈមមុខនឹងកង្វះខាតស្បៀងអាហារ និងភាពគ្មានអនាម័យនៅជុំវិញតំបន់ដែលរស់ក្នុងទីក្រុងភ្នំពេញ។ ការរស់នៅជនបទ ក៏មានភាពលំបាកផងដែរ ជាពិសេសនោះ អ្នកនៅតាមព្រំដែនកម្ពុជា-វៀតណាម ដោយសារតែមានទាហានវៀតណាមបានឈរជើងនៅទីនោះជាមួយពួកគេ។

សាស្ត្រាចារ្យ **ឆេនដ័លរ័** បានពន្យល់បន្ថែមទៀតថា ហេតុផលដទៃទៀតក្រៅពីការទម្លាក់គ្រាប់បែក គឺសង្គ្រាមរបស់សហរដ្ឋអាមេរិកប្រឆាំងនឹងកុម្មុយនីស្តវៀតណាម។ សហរដ្ឋអាមេរិក បានផ្តោតលើការទម្លាក់គ្រាប់បែកនៅតាមផ្លូវហូជីមិញ *(Ho Chi Minh)* ដែលចូលតាមច្រកឆ្លងកាត់ប្រទេសកម្ពុជា ចូលទៅកាន់វៀតណាមខាងជើង និងវៀតណាមខាងត្បូង ហើយនិង ប្រទេសឡាវ។ យោងទៅតាមការដកស្រង់ដែលគាត់បានសិក្សាស្រាវជ្រាវ សាស្ត្រចារ្យ **ឆេនដ័លរ័** បានថ្លែងថា ប្រជាពលរដ្ឋកន្លះលាននាក់ បានភៀសខ្លួនពីការវាយប្រហារនេះ។

### *ក.៣. ការអនុវត្តន៍គោលនយោបាយក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ*

សាក្សីបានកត់សម្គាល់ថា មានគម្លាតរវាងអ្វីទៅជាគោលបំណងរបស់គណបក្ស ហើយនិងអ្វីទៅជាលទ្ធផលទទួលបានជាក់ស្តែង។ គោលនយោបាយមិនដែលមានបំណងចង់បោះបង់ចោល ឬមិនមានចេតនាមិនអើពើទេ ក៏ប៉ុន្តែ នីតិវិធីនៃការអនុវត្តន៍គឺផ្សេងៗគ្នាពីទីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត។ សាស្ត្រាចារ្យ **ឆេនដ័លរ័** បាននិយាយថា កន្លែងដែលមាន "ប្រជាជនថ្មី" មានចំនួនតិច ហើយនិងកម្មាភិបាលដែលមិនមានបទពិសោធន៍ បានរាយការណ៍ថា បានបំពេញតួនាទីយ៉ាងរលូន។ គោលនយោបាយរបស់បក្ស គឺផ្តោតជាពិសេសទៅលើអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំងសត្រូវ ហើយក៏មានការិវឌ្ឍន៍ផងដែរដូចជា៖ "ជាទូទៅការបោសសម្អាតដែលផ្អែកទៅលើការរើសអើងជាតិសាសន៍ កម្រកើតមានណាស់....ការបោសសម្អាតពាក់ព័ន្ធទៅនឹងក្រុមជនជាតិភាគតិចនោះ គឺធ្វើឡើងនៅចុងរបបឯណោះ មិនមែនធ្វើនៅដើមរបបនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧"។

ជាពិសេស លោកសាស្ត្រាចារ្យ **ឆេនដ័លរ័** បានសង្កត់ធ្ងន់ថា ការគំរាមដែលនឹងទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក គឺជាហេតុផលរបស់ខ្មែរក្រហមសម្រាប់ធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែ

ការពិតនោះ សហរដ្ឋអាមេរិកមិនមានផែនការទម្លាក់បែកដើម្បីវាយប្រហារទីក្រុងនោះទេ។ គាត់បាននិយាយបន្ថែមទៀតថា ការគិតគូរពិចារណាមនុស្សធម៌ គឺជាហេតុផលមួយផ្នែកនៃការជម្លៀស ដោយសារតែមិនមានស្បៀងអាហារគ្រប់គ្រាន់ដើម្បីចិញ្ចឹមប្រជាជនគ្រប់គ្នានៅទីក្រុង។ សាស្ត្រាចារ្យ **ឆេនដ័ល័រ** បានធ្វើការបង្ហាញពីមនុស្សដែលគាត់បានសម្ភាសក្នុងការបោះពុម្ពសៀវភៅរបស់គាត់ "ប្រវត្តិសាស្ត្រកម្ពុជា" បានអធិប្បាយថាពួកគេមានស្បៀងអាហារហូបគ្រប់គ្រាន់នៅទីជនបទ ដោយសារតែមានអង្ករសម្រាប់បម្រុងទុក។

សាក្សីបានអះអាងថា ដើម្បីកុំឲ្យមានការរិះគន់ ជាញឹកញាប់ ថ្នាក់ក្រោមបានលាក់បាំងព័ត៌មានដែលពួកគេជឿថាអាចធ្វើឲ្យថ្នាក់លើរបស់ពួកគេមិនសប្បាយចិត្ត។ ឧទាហរណ៍ ថ្នាក់ក្រោមបានរាយការណ៍ឲ្យថ្នាក់លើរបស់ពួកគេគិតថា ការផ្គត់ផ្គង់អង្ករមានការកើនឡើង ទោះបីជាវាមិនមែនជាការពិតក៏ដោយ។ ជាការគួរឲ្យកត់សម្គាល់ សាក្សីបាននិយាយថា **អៀង ធីរិទ្ធ**[2] បានធ្វើដំណើរទៅកាន់ទីជនបទ ហើយបានត្រឡប់មកវិញដោយមានរបាយការណ៍អវិជ្ជមានមួយចំនួន "ប៉ុន្តែប្រាប់ទៅមេដឹកនាំ គឺថាអាហ្នឹងជាការងាររបស់ជនក្បត់ ជាខ្មាំងទេ មិនមែនជារបស់បក្សរបស់ខ្លួនទេ"។ គាត់បានសន្និដ្ឋានថា មានការ "បិទបាំង" ហើយប្រជាជនបានព្យាយាមបិទបាំងព័ត៌មានអាក្រក់ ដើម្បីជៀសវាងការដាក់ទោសចំពោះព័ត៌មានអវិជ្ជមាន។

សាស្ត្រាចារ្យ **ឆេនដ័ល័រ** ក៏បានកត់សម្គាល់ផងដែរ អំពីការចោទប្រកាន់លើកាសម្លាប់មនុស្សយ៉ាងហោចណាស់មានមានមនុស្សចំនួន១០០,០០០នាក់ ត្រូវបានគេសម្លាប់នៅទូទាំងប្រទេស។ គាត់បានពន្យល់នៅក្នុងសៀវភៅរបស់គាត់ថា ភាគរយនៃការសម្លាប់ គឺបណ្តាលមកពីប្រតិកម្មប្រឆាំងគ្នា។[3] តាមឲ្យដឹងមកកម្មាភិបាល បានប្រព្រឹត្តនូវអំពើនិទណ្ឌភាពក្នុងកម្រិតណាមួយ ហើយឥរិយាបថដ៏គឃ្លើនទាំងនោះ មិនធ្លាប់ត្រូវបានរាយការណ៍ជូនទៅថ្នាក់ដឹកនាំនោះទេ។ គាត់បានយល់ស្របជាមួយការសង្កេតរបស់អ្នកប្រវត្តិសាស្ត្រ **ស្ទីវ ហេដឌ័រ** ដែលថាថ្នាក់ដឹកនាំតំបន់ និងភូមិភាគ បានដាក់ការណែនាំមិនច្បាស់លាស់ហើយក៏មិនបានធានាថា កម្មាភិបាលមូលដ្ឋានបានគោរពតាមនោះដែរឬទេ។ សាស្ត្រាចារ្យ **ឆេនដ័ល័រ** ក៏បានគាំទ្រផងដែរចំពោះការសន្និដ្ឋានរបស់លោក **ហេដឌ័រ** ថា កម្មាភិបាលមូលដ្ឋាន ជាអ្នកបានកាប់សម្លាប់ គឺមិនបានស្តាប់បញ្ជាឲ្យបានច្បាស់លាស់នោះទេ ហើយយល់ឃើញថា ខ្លួនត្រូវបានផ្តល់នូវសិទ្ធិធំទូលាយដើម្បីកំណត់ថាអ្នកណាជាសត្រូវ។ ជាការគួរឲ្យកត់សម្គាល់នោះ នៅពេលដែលសាស្ត្រាចារ្យ **ឆេនដ័ល័រ** ជឿជាក់ថា កម្មាភិបាលមូលដ្ឋានមិនបានស្តាប់តាមបទបញ្ជានៅពេលខ្លះនោះ ទោះបីជាយ៉ាងនេះក្តីក៏ដោយ គាត់បានសង្កត់ធ្ងន់ថាថ្នាក់ដឹកនាំជាន់ខ្ពស់ក៏នៅតែទទួលខុសត្រូវនូវអ្វីដែលបានកើតឡើងនៅក្នុងរបបនោះដដែល។

> *ខ្ញុំគិតថា ខ្ញុំគួរតែលើកឡើងអំពីគំនិតរបស់ខ្ញុំ។ យើងត្រូវតែទទួលយកនូវគំនិតដែលថាអ្នកដឹកនាំជាន់ខ្ពស់ត្រូវតែទទួលខុសត្រូវទៅលើអ្វីដែលខ្លួនបានដឹកនាំ ព្រោះខ្លួនជាអ្នកដឹកនាំប្រទេស។*

ទាក់ទិនទៅនឹងជនជាប់ចោទ **អៀង សារី** និង **នួន ជា** សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានឃើញឯកសារ ដែលសរសេរដោយលោក **សុន សេន** ដែលបានផ្ញើទៅឲ្យជនជាប់ចោទទាំងពីររូបនេះ។ ខណៈពេលដែលគូសបង្ហាញពីរបៀបក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់សាក្សី ស្តីពីការបញ្ជាឲ្យកម្ទេចខ្មាំង ដែលធ្វើឡើង

ដោយថ្នាក់លើ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានឆ្លើយតបថា មានឯកសារសរសេរ ហើយបានផ្ញើពី **សុន សេន** ទៅឲ្យ **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**"[4] ដែលជំរុញឲ្យ **ឌុច** បន្តការខិតខំប្រឹងប្រែងធ្វើការងារកម្ទេចខ្មាំង។ ដោយសារតែឯកសារនេះមិនត្រូវបានចុះហត្ថលេខា ក៏ប៉ុន្តែត្រូវបានយកមកអនុវត្តតាមនោះ លោក **ឆេនដ៍ល័រ** បានផ្តល់យោបល់ថា ឯកសារទាំងនេះ ត្រូវបានស្គាល់ថាមកពី "ថ្នាក់លើ"។ យ៉ាងណាមិញ លោក **ឆេនដ៍ល័រ** បានបកស្រាយថា គឺមានតែ **ឌុច** តែម្នាក់គត់ ដែលមានការទំនាក់ទំនងជាមួយ **សុន សេន** ហើយមិនមានទំនាក់ទំនងជាមួយនឹងគណបក្សទាំងមូលនោះទេ។

### *ក.៤. សំណួររបស់ជនជាប់ចោទ នួន ជា ទៅកាន់សាក្សី*

នៅសប្តាហ៍នេះ ជនជាប់ចោទលោក **នួន ជា** បានសួរសំណួរសាក្សីអំពី (ទី១) មូលហេតុនៃជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម (ទី២) កំណើតបក្សកុម្មុយនីស្តកម្ពុជា។[5] សាក្សីបានឆ្លើយតបទៅនឹងសំណួរទី១របស់ជនជាប់ចោទ **នួន ជា** ថា ជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម គឺមានតាំងពីយូរណាស់មកហើយក្នុងប្រវត្តិសាស្ត្រ អំពីការមិនទុកចិត្តគ្នាទៅវិញទៅមក។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បាននិយាយថា ប្រទេសទាំងពីរនេះត្រូវចែករំលែកការទទួលខុសត្រូវក្នុងការប៉ះទង្គិចគ្នា។

ទាក់ទងទៅនឹងសំណួរទី២ សាក្សីបានពន្យល់ថា "បក្សកុម្មុយនីស្តកម្ពុជា គឺជាឈ្មោះនៃចលនាកុម្មុយនីស្តមួយកើតឡើងនៅឆ្នាំ១៩៧៦" ហើយបក្សនេះផ្ទាល់ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤០ គឺនៅពេលដែលចលនាបក្សកុម្មុយនីស្តកម្ពុជា និងវៀតណាម បានមានគោលបំណងដើម្បីផ្តួលរំលំអំណាចរបស់អាណានិគមបារាំង ចេញពីប្រទេសឡាវ វៀតណាម និងកម្ពុជា។ ពិចារណាលើបញ្ហាទាំងនេះ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បាននិយាយថា វាគួរឲ្យជឿផងដែរថា បក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈទំនាក់ទំនងជាមួយប្រទេសវៀតណាម។ យ៉ាងណាមិញ ឥទ្ធិពលរបស់វៀតណាមមកលើបក្សត្រូវបានកាត់បន្ថយនៅឆ្នាំ១៩៦៧ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានធ្វើសមាជបក្សរបស់ខ្លួនជាលើកដំបូង។ បន្ទាប់មកទៀត សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានបង្ហាញថា ឥទ្ធិពលវៀតណាមត្រូវបានបំបាត់ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំលក្ខន្តិកៈក្នុងអំឡុងពេលសង្គ្រាមស៊ីវិល។[6]

### *ក.៥. ការរកឃើញចំពោះជនជាប់ចោទ ខៀវ សំផន*

លោកសាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានមានប្រសាសន៍ថា គាត់បានតាមដានយ៉ាងចាប់អារម្មណ៍អំពីអាជីពរបស់ជនជាប់ចោទ **ខៀវ សំផន** និងបានសិក្សាពីជីវប្រវត្តិរបស់ជនជាប់ចោទរូបនេះយ៉ាងយកចិត្តទុកដាក់ជាទីបំផុត។ សាក្សីបានផ្តល់សក្ខីកម្មថា នៅឆ្នាំ១៩៦២ ជនជាប់ចោទ **ខៀវ សំផន** ត្រូវបានគេទទួលស្គាល់ថាជាមនុស្សសុចរិតថ្លៃថ្នូរម្នាក់ និងជាបុគ្គលដ៏កម្រម្នាក់នៅក្នុងចំណោមអ្នកដែលគិតគូរពីប្រជាជនរបស់គាត់។ យោងទៅតាមសាស្ត្រាចារ្យ **ឆេនដ៍ល័រ** ប្រជាប្រិយភាពរបស់ **ខៀវ សំផន** នៅរដ្ឋសភាក្នុងឆ្នាំ១៩៦៦ បានគំរាមកំហែងដល់អំណាចផ្តាច់ការរបស់ **សម្តេចសីហានុ** ហើយប្រការបែបនេះអាចត្រូវបានគេយល់ថាជាសកម្មភាពឈ្លានពានអំណាចពីព្រះអង្គ។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានមានប្រសាសន៍ថា កាលៈទេសៈ

ទាំងនេះ បានបង្ខំឲ្យលោក **ខៀវ សំផន** រត់គេចពីក្រុងភ្នំពេញ ហើយបានស្វែងរកទីជម្រកសុវត្ថិភាពនៅក្នុងព្រៃ។[7]

នៅពេលដែលសមាជិកភាពរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានធ្វើឡើងយ៉ាងសម្ងាត់នោះ ខ្សែជីវិតរបស់ **ខៀវ សំផន** និងអាកប្បកិរិយានៃការទទួលខុសត្រូវរបស់គាត់បានធ្វើឲ្យសាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានសន្និដ្ឋានថា ក្រោយមក **ខៀវ សំផន** ពិតជាបានក្លាយជាសមាជិករបស់បក្ស។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានគូសបង្ហាញថា **ខៀវ សំផន** បានក្លាយទៅជាសមាជិកម្នាក់នៃគណៈមជ្ឈិមក្នុងឆ្នាំ១៩៧១ ហើយបានក្លាយជា "សមាជិកពេញសិទ្ធិមួយរូប" នៃបក្សកុម្មុយនីស្តកម្ពុជា នៅខែកក្កដា ឆ្នាំ១៩៧៦។ ជនជាប់ចោទ **ខៀវ សំផន** បានកាន់តួនាទីខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលគាត់ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ក៏ប៉ុន្តែ ការទទួលខុសត្រូវរបស់គាត់នៅតែពុំមាននរណាម្នាក់បានដឹងប្រាកដឡើយ ហើយសាក្សីបានទទួលស្គាល់ថា "យើងមិនបានដឹងទាំងស្រុងពីអ្វីដែលជាភារកិច្ចនៅក្នុងនោះហ្នឹងឡើយ" ។

### *ក.៦. ប្រភពនៃវិធីសាស្ត្រស្រាវជ្រាវព័ត៌មាន*

លោកសាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានពន្យល់ថា ជាធម្មតាគាត់ធ្វើការងារតែម្នាក់ឯង នៅពេលដែលគាត់ប្រមូលព័ត៌មានសម្រាប់សរសេរសៀវភៅរបស់គាត់ តែពេលខ្លះក៏គាត់ត្រូវការអ្នកបកប្រែមកជាមួយផងដែរ។ កិច្ចសម្ភាសន៍ភាគច្រើនត្រូវបានធ្វើឡើង ក្នុងចន្លោះឆ្នាំ១៩៨៥ និង ១៩៩៣ ហើយធ្វើឡើងដោយសម្ងាត់ ឬក៏មានវត្តមានអ្នកដទៃទៀត អាស្រ័យលើបញ្ហាដែលនឹងត្រូវលើកឡើងយកមកពិភាក្សា។ កិច្ចសម្ភាសន៍ទាំងនេះ ត្រូវបានធ្វើឡើងក្នុងប្រទេសផ្សេងៗដូចជា នៅកម្ពុជា កាណាដា បារាំង និងប្រទេសថៃ។ ប្រជាជនភាគច្រើនដែលគាត់ត្រូវបានសម្ភាសនោះ គឺជាជនភៀសខ្លួន។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានពន្យល់ថា ក្នុងអំឡុងពេលនៃការសិក្សាស្រាវជ្រាវរបស់គាត់ គាត់មិនបានស្វែងរកយោបល់ពិសេសណាមួយនោះទេ ហើយជំនួសមកវិញ គាត់គ្រាន់តែបានស្តាប់ការសម្ភាសន៍នានាដែលគាត់បានជួបប្រទះតែប៉ុណ្ណោះ។

ក្នុងវគ្គសួរសំណួរដេញដោលទៅកាន់សាស្ត្រាចារ្យ **ឆេនដ៍ល័រ** មេធាវីការពារក្តី បានចោទសួរដេញដោលគាត់បន្ថែមស្តីពីប្រភពព័ត៌មានដែលគាត់ទទួលបាន។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានអានឯកសារដែលបានដកស្រង់ចេញពីព័ត៌មានបន្ថែមនៅចុងអត្ថបទនៃដីកាដំណោះស្រាយ ដែលពីមុនមកនោះ មិនមានសម្រាប់គាត់ឡើយ។ គាត់ទើបតែត្រូវបានគេផ្តល់ឯកសារថតចម្លងនៃដីកាដំណោះស្រាយ នៅពេលដែលគាត់បានមកដល់ទីក្រុងភ្នំពេញ គឺមុនពេលផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ។ គាត់បានទទួលស្គាល់ថា គាត់មិនបានត្រួតពិនិត្យព័ត៌មានបន្ថែមនីមួយៗនៅចុងអត្ថបទក្នុងដីកាដំណោះស្រាយនោះទេ ទោះបីជាព័ត៌មានថ្មីៗទាំងនោះបានធ្វើឲ្យគាត់មានការយល់ដឹងកាន់តែច្រើន ហើយនិង អាចជួយធ្វើឲ្យសៀវភៅរបស់គាត់កាន់តែមានភាពល្អប្រសើរឡើងក៏ដោយ ក៏ព័ត៌មានទាំងនេះមិនបានផ្លាស់ប្តូរការសន្និដ្ឋានរបស់គាត់ទេ។

សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានពន្យល់ថា គាត់បានអានឯកសារមួយចំនួន ដើម្បីត្រៀមខ្លួនក្នុងការផ្តល់សក្ខីកម្មរបស់គាត់។ គាត់បានធ្វើឲ្យមានភាពប្រសើរឡើងវិញនូវការចងចាំរបស់គាត់ ដោយបានធ្វើការសិក្សាពីសៀវភៅជាច្រើនដែលអាចរកបានជាសាធារណៈ ដែលក្នុងនោះរួមមាន *សៀវភៅការសិក្សាស្តីពីការសាលា*

*ក្តីខ្មែរក្រហម*[8] និង *ការសម្លាប់បេក្ខជនទាំងប្រាំពីរនាក់*[9]។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានទាក់ទងជាមួយនឹងអ្នកជំនាញដទៃទៀត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីយល់ពីការប្រតិបត្តិនៃ **អ.វ.ត.ក** ហើយការផ្តល់សក្ខីកម្មរបស់សាក្សីដែលបានធ្វើកន្លងមក។ នៅពេលដែលមានសំណួរសួរទាក់ទងនឹងទំនាក់ទំនងរបស់គាត់ជាមួយនឹងលោក **ស្ទីវ ហេដឌ័រ** ដែលជាប្រវត្តិសាស្ត្រវិទូម្នាក់បានធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញា សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានឆ្លើយតបថាគាត់បានអានការបោះពុម្ពផ្សាយរបស់លោក **ហេដឌ័រ** ហើយពួកគេ បានឆ្លើយឆ្លងគ្នាតាមរយៈអ៊ីម៉ែល។ បន្ថែមជាងនេះទៅទៀត តាមឲ្យដឹងមក សាស្ត្រាចារ្យ **ឆេនដ៍ល័រ** និងលោក **ហេដឌ័រ** បានផ្លាស់ប្តូរឯកសារគ្នាដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជាទៅវិញទៅមក។ ក៏ប៉ុន្តែ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានសង្កត់ធ្ងន់ថា លោក **ហេដឌ័រ** មិនបានផ្តល់ឲ្យគាត់នូវឯកសារចម្បងណាមួយ ដែលជាឯកសារដែលគាត់មិនអាចស្វែងរកបាននោះឡើយ។

ទាក់ទងទៅនឹងចំនួនអ្នកស្លាប់ដែលបានដកស្រង់ក្នុងសៀវភៅរបស់គាត់ សាក្សីបានពឹងផ្អែកទៅលើប្រជាសាស្ត្រវិទូដ៏ជំនាញជាច្រើននាក់ដូចជា លោក **ផាទ្រិក អេវ៉រលីន** *(Mr. Patrick Heuveline)* និង លោក **ឡារ៉ែនស្គី** *(Mr. Marek Slinwinski)*។ សាក្សីបានទទួលស្គាល់ពីភាពមិនស៊ីចង្វាក់គ្នា ចំពោះចំនួនអ្នកស្លាប់ក្នុងសៀវភៅរបស់គាត់ ហើយបានពន្យល់ថា គឺមានតែការវាយតម្លៃប៉ាន់ស្មានតែប៉ុណ្ណោះ ទើបអាចយកមកប្រើប្រាស់បាន។ គាត់បានគូសបញ្ជាក់ថា មកដល់ពេលនេះ នៅតែមិនទាន់មានតួលេខត្រឹមត្រូវស្តីពីចំនួនអ្នកស្លាប់ក្នុងរបបខ្មែរក្រហមឡើយ។ សាក្សីបានពន្យល់ថា គាត់មិនអាចសួរអ្នកជំនាញប្រជាសាស្ត្រ អំពីដំណើរការដែលពួកគេប្រើប្រាស់សម្រាប់ដឹងពីតួលេខ ដែលជាលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ពួកគេនោះទេ។ ក្នុងករណីណាក៏ដោយ លោកសាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានបញ្ជាក់ពីភាពទំនុកចិត្តលើតួលេខ ដែលបានមកពីលោក **ផាទ្រិក អេវ៉រលីន** និង លោក **ឡារ៉ែនស្គី**។

### *ក.៧. វត្តមានរបស់វៀតណាមក្នុងប្រទេសកម្ពុជាបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ*

យោងតាមសាក្សី កងទ័ពវៀតណាម បានជួបប្រទះឃើញឯកសារជាច្រើននៅមន្ទីរស-២១ នៅពេលដែលពួកគេបានមករំដោះប្រទេសចេញពីពួកខ្មែរក្រហម ហើយជាភស្តុតាងនោះឃើញថា កងទ័ពវៀតណាមបានចំណាររលើឯកសារចម្លើយសារភាពមួយចំនួន។ សាក្សីក៏បានកត់សម្គាល់ផងដែរថា ឯកសារចម្លើយសារភាពដោយមនុស្សសំខាន់ៗដែលឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានបាត់។ ជាឧទាហរណ៍ គាត់បានសន្និដ្ឋានថា ចម្លើយសារភាពរបស់អនុលេខាភូមិភាគឦសាន លោក **នៃ សារ៉ាន់** ហៅ **យ៉ា** ត្រូវបាន "កម្ទេច" ដោយកងទ័ពវៀតណាម។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានពន្យល់ពីទស្សនៈនៃ "ការកម្ទេច" ក្នុងលក្ខណៈដូចខាងក្រោម៖

> *ប្រសិនបើយើងនិយាយពីខាងក្រៅបក្ស គឺមានឯកសារជាច្រើនដែលគេបង្កើត ហើយនិងជ្រើសរើសឡើង ហើយនិងធ្វើការប្រមូលផ្តុំតិចតួច ឬក៏ដកចេញនូវឯកសារណាមួយដែលគេយល់ថាមិនគួរឲ្យចាប់អារម្មណ៍.....*

សាក្សីបានបន្ថែមទៀតថា កងទ័ពវៀតណាមបានយកឯកសារចេញពីប្រទេសកម្ពុជា ទៅរក្សាទុកនៅប្រទេសវៀតណាម ហើយឯកសារទាំងនោះមិនអាចរកជាសាធារណៈបានទេ។ ក៏ប៉ុន្តែ សាក្សីបានបញ្ជាក់យ៉ាងលឿនថា គាត់មិនសូវជាច្បាស់ថា តើកងទ័ពវៀតណាមបានជាប់ពាក់ព័ន្ធក្នុងការបោសសម្អាតជាប្រព័ន្ធនៃចម្លើយសារភាពដែរឬអត់។ នៅពេលមានការសង្កត់ធ្ងន់លើប្រធានបទនៃការបោសសម្អាត សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បាននិយាយថា វាមិនគួរជាបញ្ហាច្រើនសន្ធឹកសន្ធាប់ពេកកើតមានឡើង ដោយសារតែនៅពេលដែលមានការបង្ហាញពីភស្តុតាងនៃការកម្ទេច វាមិនមែនជាព័ត៌មានគ្រប់គ្រាន់ដើម្បីគាំទ្រចំពោះការសន្និដ្ឋាននេះឡើយ។

សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងពេលរបបសាធារណរដ្ឋប្រជាមានិត្យកម្ពុជា "ពួកគេបានប្រឹងប្រែង ដើម្បីឲ្យមានការចងក្រងនូវប្រវត្តិសាស្ត្រដែលមានកម្រិតមួយ ដែលគេចាត់ទុកថាជាបិសាច និងគួរខ្ពើមរអើម ដែលបានធ្វើមកលើប្រជាជនកម្ពុជាធម្មតា ចំពោះអ្វីដែលគេធ្វើនោះ។" គាត់បានបកស្រាយលម្អិតដូចខាងក្រោម៖

> *តាមពិតនៅក្នុងការជំនុំជម្រះ **ប៉ុល ពត** និង **អៀង សារី** ពីរឿងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ហ្នឹង ធ្វើឡើងនៅឆ្នាំ១៩៧៩ នៅក្នុងសៀវភៅនិយាយអំពីសៀវភៅសិក្សាដើមទសវត្សរ៍ឆ្នាំ១៩៨០ ហើយនិងក៏មានការបង្កើតជាទិវាចងកំហឹងនៅថ្ងៃទី២០ ខែឧសភាហ្នឹងហើយក្រោយមកគេបង្កើតនូវសារមន្ទីរប្រល័យពូជសាសន៍។ នេះហើយ ជាការងារមួយដែលអាចនឹងបង្ហាញថា មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើការងារនេះ ហើយដើម្បីពិនិត្យមើលនូវក្រុមមនុស្សមួយចំនួន ដែលប្រព្រឹត្តនូវអំពើអាក្រក់។ ខ្ញុំប្រើនៅក្នុងសេចក្តីដកស្រង់ គឺមាន **ប៉ុល ពត** និង **អៀង សារី** ដែលគេកាត់ទោសនោះ។*

ថ្វីបើមានកិច្ចប្រឹងប្រែងដើម្បីស្តីបន្ទោសទៅលើសោកនាដកម្មរបស់ខ្មែរក្រហមមកលើ **ប៉ុល ពត** និង **អៀង សារី** ស្តីពី "អំពើប្រល័យពូជសាសន៍" សាក្សីបានបន្តអះអាងថា វាមិនអាចធ្វើទៅរួចទេដែលមានតែមនុស្សពីរនាក់គត់ប៉ុណ្ណឹង ជាអ្នកទទួលខុសត្រូវលើអ្វីគ្រប់យ៉ាង ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលនៃរបបនោះឡើយ។ យោងទៅតាមសាស្ត្រាចារ្យ **ឆេនដ៍ល័រ** និយាយថា សហគមន៍អន្តរជាតិ បានចាត់ទុកការជំនុំជម្រះលើ **ប៉ុល ពត** និង **អៀង សារី** នៅឆ្នាំ១៩៧៩ ថាជា "តុលាការខេនហ្គូរូ" *(Kangaroo Court)* ហើយគាត់បានចាត់ទុកតុលាការនៅពេលនោះថាជា ការជំនុំជម្រះ "មិនមានហេតុផលសមស្រប" គួរឲ្យគោរពបានឡើយ។ សាស្ត្រាចារ្យ **ឆេនដ៍ល័រ** បាននិយាយថា "មេធាវីការពារក្តី ដែលត្រូវបានតែងតាំងឲ្យ **ប៉ុល ពត** និង **អៀង សារី** បានលើកឡើង និងនិយាយថា មនុស្សទាំងអស់នេះ គឺជាមនុស្សឆ្កួត ហើយតុលាការគួរតែកាត់ទោសគាត់ទៅ"។

### *ក.៨. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

សាក្សីជំនាញ មានសភាពស្ងប់ស្ងាត់ ហើយបានចូលរួមកិច្ចសហការយ៉ាងច្រើនក្នុងកិច្ចដំណើរការនីតិវិធីនេះ។ មានពេលខ្លះ សាក្សីមើលទៅហាក់បីដូចជាមានភាពស្មុគស្មាញ នៅពេលមានបញ្ហានៃបកប្រែ

កើតមានឡើង ឬក៏នៅពេលដែលភាពគួរឲ្យជឿជាក់របស់គាត់ ត្រូវបានប្រឈមនឹងសួរដេញដោល។ សាក្សី គឺមានភាពប្រុងប្រយ័ត្នក្នុងការឆ្លើយចម្លើយរបស់គាត់ ហើយបានបែងចែករវាងភស្តុតាងលើអង្គហេតុ និងការសន្និដ្ឋានរបស់គាត់។ លើសពីនេះទៅទៀត គាត់ក៏បានបើកទូលាយពីប្រភពព័ត៌មាន ដែលគាត់បានអានមុនពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងបានធ្វើការសហការ នៅពេលដែលមានការស្នើសុំឲ្យផ្តល់បញ្ជីប្រភពព័ត៌មានដែលគាត់បានអាន តាំងពីពេលដែលគាត់បានមកដល់ទីក្រុងភ្នំពេញម្ល៉េះ។ ទោះបីជាគាត់បានបដិសេធមិនធ្វើអធិប្បាយលើសេចក្តីថ្លែងការណ៍របស់លោក **ហេងឌ័រ** ដែលបានធ្វើជាមួយគាត់ជាការសម្ងាត់ក៏ដោយ ក៏គាត់បានប្រាប់អំពីទំនាក់ទំនង ដែលគាត់បានធ្វើនៅមុនពេលដែលបង្ហាញខ្លួននៅចំពោះមុខ **អ.វ.ត.ក** នេះដែរ។

## ខ. សក្ខីកម្មរបស់សាក្សី រ៉ចាម តុន

សាក្សី **រ៉ចាម តុន** *(TCW-៥៦៣)* ដែលគេបានស្គាល់ផងដែរថា "**ភី ភួន**" និង "**វី ជាម**"[10] មានកំណើតនៅខេត្តរតនគីរី និងជាជនជាតិចារាយ។ គាត់បានចូលរួមបដិវត្តន៍ក្នុងឆ្នាំ១៩៦៣ ហើយបានចាប់ ផ្តើមបម្រើការងារជាកងអង្គរក្ស និងជានីរសារឲ្យថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។ ក្រោយមក គាត់បានក្លាយជាប្រធានអង្គភាពរដ្ឋបាលនៃក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែ គាត់មានទំនាក់ទំនងផ្ទាល់ជាមួយនឹង **ប៉ុល ពត** និងជនជាប់ចោទបីរូបផ្សេងទៀត គាត់អាចផ្តល់សក្ខីកម្មពីទំនាក់ទំនងរបស់គាត់ជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ទាក់ទងទៅនឹងសកម្មភាព និងការធ្វើសេចក្តីសម្រេចរបស់ពួកគេ ហើយនិងរចនាសម្ព័ន្ធរបស់អង្គការនេះ។

នៅសប្តាហ៍នេះ សហព្រះរាជអាជ្ញា **សេង ប៊ុនឃាង** និងលោក **ឌេល លីសាក់** *(Mr. Dale LYSAK)* បានសួរសំណួរទៅកាន់លោក **រ៉ចាម តុន**។

### *ខ.១. ការពាក់ព័ន្ធក្នុងបក្សកុម្មុយនីស្តកម្ពុជា មុខខែមេសា ឆ្នាំ១៩៧៥*

លោក **រ៉ចាម តុន** បានថ្លែងថា បងប្រុសថ្លៃរបស់គាត់ដែលបានចូលរួមជាសមាជិកចលនាបដិវត្តន៍នេះរួចទៅហើយ បានប្រាប់គាត់ថា ការចូលរួមបដិវត្តន៍ គឺជាឱកាសដ៏ល្អមួយសម្រាប់សមាជិកជនជាតិភាគតិចដូចពួកគាត់អីចឹង។ ដោយមានការជំរុញ សាក្សីជាបន្តបន្ទាប់បានក្លាយទៅជាសមាជិកនៃសម្ព័ន្ធយុវជន និងជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦៨ ហើយនិងឆ្នាំ១៩៧១ ត្រូវបានគេគោរពទទួលស្គាល់។

សាក្សីបានថ្លែងប្រាប់ថា ដំបូងឡើយគាត់បានបម្រើការងារ ជាកងអង្គរក្សឲ្យបង **ម៉ាន** ដែលជាលេខាតំបន់ក្នុងខេត្តរតនគីរី។ ពេលឈរជើងនៅក្នុងខេត្តរតនគីរីក្នុងឆ្នាំ១៩៦៧ តាមឲ្យដឹងមក គាត់បានជួបនឹង **អៀង សារី** និង **ប៉ុល ពត**។ គាត់បានចាំថា កាលណោះ គាត់បានទទួលបញ្ជាមួយពីលោក **អៀង សារី** ឲ្យនាំសំបុត្រមួយទៅ "ខាងវៀតណាម"។ នៅក្នុងខែធ្នូ ឆ្នាំដដែលនោះ សាក្សីបានជូន **ប៉ុល ពត** ទៅកាន់មន្ទីរពេទ្យមួយក្នុងប្រទេសវៀតណាម ដើម្បីព្យាបាលជម្ងឺគ្រុនចាញ់។ ក្រៅពីបម្រើការងារជាកងអង្គរក្ស លោក **រ៉ចាម**

**តុន** បានថ្លែងថា គាត់ក៏បានបម្រើការងារជានីរសារ និងនាំសំបុត្ររវាង **ប៉ុល ពត** ដែលកាលណោះនៅភាគខាងជើងទន្លេសេសាន និងលោក **អៀង សារី** ដែលឈរជើងនៅភាគខាងត្បូងនៃទន្លេនេះ។

### *ខ.២. រចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនង*

សាក្សីបានផ្តល់សក្ខីកម្មថា នៅពេលដែលគាត់ធ្វើជាកងអង្គរក្សឲ្យមេដឹកនាំជាន់ខ្ពស់ គាត់បានយល់ដឹងដោយផ្ទាល់ទៅនឹងរចនាសម្ព័ន្ធភូមិសាស្រ្ត រដ្ឋបាល ទំនាក់ទំនង និងការដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនោះ នៅក្នុងតំបន់ដែលជាមូលដ្ឋានរបស់ **ប៉ុល ពត**។

### *ខ.២.ក. ការិយាល័យ ១០០ និង ១០២*

យោងតាមលោក **រ៉ចាម តុន** មេដឹកនាំសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជា គឺបានមានមូលដ្ឋាននៅក្នុងខេត្តរតនគីរី ចាប់តាំងពីឆ្នាំ១៩៦៧ រហូតដល់ដើមឆ្នាំ១៩៧០។ **ប៉ុល ពត** បានស្នាក់នៅមន្ទីរ១០០ ហើយ **អៀង សារី** ស្នាក់នៅមន្ទីរ១០២។ លោក **រ៉ចាម តុន** បាននិយាយថា ទោះបីជាការិយាល័យទាំងពីរ នៅឆ្ងាយពីគ្នាត្រឹមតែបីគីឡូម៉ែត្រក៏ដោយ ក៏វាមានការលំបាកក្នុងការធ្វើដំណើរពីការិយាល័យមួយទៅការិយាល័យមួយទៀត (ដោយសារតែទីតាំងនីមួយៗគឺនៅក្នុងព្រៃជ្រៅ) ហើយសម្បូរទៅដោយគ្រាប់បែក។ លើសពីនេះទៀត គាត់បានរៀបរាប់ពីទំនាក់ទំនាក់យ៉ាងជិតស្និទ្ធរវាង **ប៉ុល ពត** និង **អៀង សារី** ថា៖

> *ហ្នឹងគឺថាស្រឡាញ់គ្នាដូចជាបងប្អូនអ៊ីចឹង ស្រឡាញ់គ្នាក្នុងនាមជាមិត្តរួមតស៊ូជាមួយគ្នា ឃើញស្រឡាញ់ៗគ្នា អត់មានអីទៀត គឺថាគោរពគ្នាទៅវិញទៅមក ហើយស្រឡាញ់គ្នាទៅវិញទៅមក។ ហើយមានអីៗ ឃើញគាត់ចែកគ្នាហូបហ្នឹង គាត់ចែកគ្នាហូប ស្រឡាញ់ល្អតើ ឃើញគំរូល្អ យើងខាងក្រោមៗ យើងអ៊ីចឹងក៏ល្អដែរ ឃើញថាល្អដែរ គាត់ល្អអ៊ីចឹង។*

តាមឲ្យដឹងមកលោក **អៀង សារី** ជាអ្នកទទួលខុសត្រូវការិយាល័យ១០០ និង ១០២ នៅពេលដែល **ប៉ុល ពត** មិននៅ។ **សុន សេន** ដែលជាអ្នកទទួលខុសត្រូវផ្នែកកិច្ចការយោធា បានមកដល់ខេត្តរតនគីរី ក្នុងឆ្នាំ១៩៦៨។ គាត់ក៏បាននឹកឃើញឡើងវិញថា កាលណោះ **គុយ ធួន** និង **នួន ជា** បានមកធ្វើទស្សនកិច្ចខ្លីមួយនៅខេត្តរតនគីរី។

### *ខ.២.ខ. មន្ទីរស-៧១*

លោក **រ៉ចាម តុន** បានផ្តល់សក្ខីកម្មថា **ប៉ុល ពត** និងប្រពន្ធរបស់គាត់បានធ្វើដំណើរទៅប្រទេសវៀតណាម និងប្រទេសចិន នៅចុងឆ្នាំ១៩៦៩។ ពេលត្រឡប់មកវិញ នៅខែឧសភា ឆ្នាំ១៩៧០ **ប៉ុល ពត** បានផ្លាស់ប្តូរការិយាល័យពីខេត្តរតនគីរីទៅខេត្តកំពង់ចាមវិញ។ ការិយាល័យថ្មីនៅខេត្តកំពង់ចាម ត្រូវបានគេស្គាល់ថាជា "មន្ទីរស-៧១" ហើយតាមឲ្យដឹងមក វាជាកន្លែងដែល **ប៉ុល ពត** ជនជាប់ចោទ **នួន ជា** និងជនជាប់ចោទ **ខៀវ សំផន** បានឈរជើងជាមូលដ្ឋាន។ នៅពេលដែល **ប៉ុល ពត** មិននៅ ជនជាប់ចោទ **នួន ជា** ឬ **ខៀវ សំផន** ជាអ្នកទទួលខុសត្រូវលើការិយាល័យនេះ។ លោក **រ៉ចាម តុន** បានផ្តល់សក្ខីកម្មបន្ថែមទៀតថា

មានពេលខ្លះ គាត់បានអមដំណើរជាមួយនឹង **ប៉ុល ពត** ឬ **នួន ជា** ទៅ "មូលដ្ឋានដែលជាកន្លែងហ្វឹកហ្វឺនយោធា ដើម្បីប្រយុទ្ធ" ដែលសំដៅទៅលើ "សមរភូមិ"។

ម៉្យាងវិញទៀត លោក **វ៉ាចាម តុន** បានចង្អុលបង្ហាញថា តាមឲ្យដឹងមក **អៀង សារី** និង **សុន សេន** បានស្នាក់នៅក្នុងខេត្តរតនគីរីរហូតដល់ឆ្នាំ១៩៧១ ដែលជាទីកន្លែង **អៀង សារី** "ទទួលខុសត្រូវ" ហើយ **សុន សេន** នៅតែទទួលខុសត្រូវបញ្ហាកិច្ចការយោធាដដែល។ លោក **អៀង សារី** បានធ្វើដំណើរទៅទីក្រុងប៉េកាំងនៅដើមឆ្នាំ១៩៧១ ហើយបានស្នាក់នៅទីនោះរហូតដល់មាន "ការរំដោះ" នៅខែមេសា ឆ្នាំ១៩៧៥។ លោក **វ៉ាចាម តុន** បាននិយាយថា គាត់បានដឹងតាមរយៈការប្រកាសវិទ្យុថា លោក **អៀង សារី** នៅទីក្រុងប៉េកាំង "គឺជាបេសកជនពិសេសរបស់ចលនាតស៊ូរបស់ **សម្តេចសីហនុ** ឬ **សម្តេចឪ**"។

យោងទៅតាមសាក្សី ជនជាប់ចោទ **ខៀវ សំផន** "បានសរសេរគ្រប់យ៉ាង" សម្រាប់ "រណសិរ្សរួបរួមជាតិកម្ពុជា"។ សាក្សីបាននិយាយថា គាត់បានអានឯកសារនានា ដែលនិពន្ធឡើងដោយ **ខៀវ សំផន** ហើយខ្លឹមសារនៃអត្ថបទទាំងនោះត្រូវបានប្រកាសតាមវិទ្យុ។ **វ៉ាចាម តុន** ក៏បាននិយាយផងដែរថា **ខៀវ សំផន** បានផ្តល់វគ្គបង្រៀនស្តីអំពី "កម្លាំងរណសិរ្សហ្នឹង ថាធ្វើម៉េចៗ គាត់បង្រៀនដែរ ឲ្យយល់ពីកម្លាំងរណសិរ្សហ្នឹង។ សារៈសំខាន់អ្វីខ្លះ នៅក្នុងប្រទេសយ៉ាងម៉េច ក្រៅប្រទេសយ៉ាងម៉េច។"

### *ខ.២.គ. ការិយាល័យ ប-៥*

សាក្សីបាននិយាយថា នៅចុងឆ្នាំង១៩៧៣ ការិយាល័យ ប-៥ ក្នុងភូមិតាំងភូន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បានក្លាយទៅជាទីបញ្ជាការសម្រាប់ "សមរភូមិមុខ" ហើយនិងជាកន្លែងការិយាល័យចល័ត[11] សម្រាប់កិច្ចការឃ្លាំមើល។ តាមឲ្យដឹងមក **ប៉ុល ពត** បានស្នាក់នៅក្នុងការិយាល័យជាអចិន្ត្រៃយ៍ក្នុងអំឡុងពេលរដូវប្រាំង និងបានត្រឡប់ទៅមន្ទីរស-៧១ នៅរដូវវស្សា។ លោក **នួន ជា** ហើយ **ខៀវ សំផន** បាននៅសមរភូមិខាងក្រោយ ហើយពួកគាត់បានត្រឹមតែទៅការិយាល័យ ប-៥ សម្រាប់ការប្រជុំពីរបីលើកប៉ុណ្ណោះ។

## *ខ.៣. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

យោងទៅតាមលោក **វ៉ាចាម តុន** ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំមួយ ដែលបានធ្វើឡើងក្នុងខែមេសា ឆ្នាំ១៩៧៥ នៅការិយាល័យ ប-៥។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មានលោក **ប៉ុល ពត** លោក **នួន ជា** លោក **ខៀវ សំផន** លោក **តា ម៉ុក** លោក **សុន សេន** លោក **ក្ឌួយ ធុន** លោក **វន វ៉េត** លោក **ចេង អន** និង **សោ ភឹម** បានចូលរួមកិច្ចប្រជុំនោះ។ ចំណែកឯលោក **អៀង សារី** នៅពេលនោះ គឺស្ថិតនៅក្នុងប្រទេសចិន។ ក្នុងកិច្ចប្រជុំនោះ តាមឲ្យដឹងមក លោក **វ៉ាចាម តុន** បានស្តាប់ឮ **ប៉ុល ពត** និយាយថា វាគ្រាន់តែជាបញ្ហានៃពេលវេលាតែប៉ុណ្ណោះ មុនពេលដែលពួកគេផ្តួលរំលំរបប **លន់ នល់**។ ជាការគួរឲ្យកត់សម្គាល់នោះ សាក្សីបានផ្តល់សក្ខីកម្មថា **ប៉ុល ពត** បានលើកឡើងពីប្រធានបទនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយលើកយកភាពជោគជ័យនៃការជម្លៀសប្រជាជនចេញពីក្រុងឧត្តុង្គ ចាត់ទុកជាផ្លូវដឹកនាំរបស់ពួកគេ។

សាក្សីបាននិយាយបន្ថែមទៀតថា បន្ទាប់ពីបទបង្ហាញរបស់លោក **ប៉ុល ពត** បានបញ្ចប់ គាត់បានកត់សម្គាល់ឃើញថា លោក **នួន ជា** បានក្រោកឈរឡើង ដោយបានបង្ហាញពីភាពចាំបាច់នៃការជម្លៀសប្រជាជនចេញ និងបានសម្តែងការគាំទ្ររបស់ទៅនឹងផែនការនេះ។ គាត់ក៏បានផ្តល់សក្ខីកម្មផងដែរថា "**ខៀវ សំផន** ក៏បានឯកភាពលើផែនការនេះដែរ។"

### *ខ.៤. ការ "រំដោះ" ទីក្រុងភ្នំពេញ*

លោក **វ៉ាចម តុន** បានចង្អុលបង្ហាញថា នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាពេលវេលាដែលខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ហើយនៅពេលនោះ គាត់បាននៅជាមួយ **ប៉ុល ពត** នៅភូមិស្តុកតោល ដែលមានចម្ងាយ១០គីឡូម៉ែត្រ ពីការិយាល័យ ប-៥។ លោក **សុន សេន** លោក **កុយ ធួន** លោក **តា ម៉ុក** និងលោក **វន វ៉េត** ក៏បានស្ថិតនៅក្នុងភូមិស្តុកតោលនោះផងដែរ ហើយពួកគេបានតាមដានយ៉ាងជាប់នូវព្រឹត្តិការណ៍នានាតាមរយៈ "ឧបករណ៍វិទ្យុទាក់ទង"។ ពីរថ្ងៃក្រោយមក នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ លោក **វ៉ាចម តុន** បានធ្វើដំណើរអមជាមួយលោក **សុន សេន** ទៅកាន់រាជធានី។ គាត់បានចាំថា នៅខណៈពេលដែលមានប្រជាជនជាច្រើនបានចាកចេញពីទីក្រុងរួចហើយក៏ដោយ ក៏នៅមានប្រជាជនជាច្រើនទៀតផងដែរបានបន្តការចាកចេញរបស់ខ្លួន នៅពេលដែលពួកគាត់បានទៅដល់ទីក្រុងភ្នំពេញ។ គាត់បាននិយាយថា មានសាកសពជាច្រើននៅតាមដងផ្លូវ ហើយមួយចំនួនបានស្អុយរលួយទៅហើយ។ គាត់បានសន្និដ្ឋានថា អ្នកទាំងនោះភាគច្រើនជាទាហាន ពីព្រោះគាត់ឃើញសាកសពមានពាក់មួកការពារ។

សាក្សីបានផ្តល់សក្ខីកម្មថា លោក **សុន សេន** បានរាយការណ៍ទៅកាន់មេដឹកនាំដទៃទៀតថា កម្លាំងខ្មែរក្រហមបានត្រួតត្រាទីក្រុងទាំងស្រុង ហើយថានៅថ្ងៃទី២០ ខែមេសា លោក **ប៉ុល ពត** និងមេដឹកនាំថ្នាក់តំបន់ និងភូមិភាគ បានចូលមក ដល់ស្ថានីយរថភ្លើង ដែលលោក **សុន សេន** បានកត់សម្គាល់ថាជាទីតាំងប្រជុំរបស់ថ្នាក់ដឹកនាំនៅពេលនោះ។ លោក **នួន ជា** និងលោក **ខៀវ សំផន** បានមកដល់នៅថ្ងៃបន្ទាប់ ហើយលោក **អៀង សារី** បានចូលរួមប្រជុំ នៅមួយសប្តាហ៍ក្រោយមកបន្ទាប់ពីការវិលត្រឡប់របស់គាត់ពីទីក្រុងប៉េងកាំងវិញ។ លោក **ប៉ុល ពត** និងជនជាប់ចោទបីរូប បានជួបជុំគ្នា ហើយបានប្រជុំជាមួយនឹងមេបញ្ជាការយោធា ដំបូងឡើយធ្វើឡើងនៅក្នុងស្ថានីយរថភ្លើង ហើយប្រហែលជាមួយសប្តាហ៍ក្រោយមកបានធ្វើនៅក្រសួងពាណិជ្ជកម្ម។ សាក្សីបានថ្លែងថា លោក **ប៉ុល ពត** លោក **នួន ជា** លោក **ខៀវ សំផន** លោក **អៀង សារី** និងលោក **សុន សេន** បានធ្វើការងារនៅក្រសួងពាណិជ្ជកម្មជាប្រចាំថ្ងៃ។ តាមឲ្យដឹងមក មេដឹកនាំទាំងនោះបានស្នាក់នៅក្នុងក្រសួងពាណិជ្ជកម្ម ប្រហែលជាអំឡុងពេលពីរសប្តាហ៍ ហើយនិងបានផ្លាស់ប្តូរទីតាំងផ្សេងៗទៀត ដោយយោងទៅតាមស្ថានភាពស្ថេរភាព។ លោក **ប៉ុល ពត** លោក **នួន ជា** លោក **ខៀវ សំផន** និងលោក **អៀង សារី** បានរស់នៅជិតគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ខណៈពេលដែលលោក **សុន សេន** លោក **តា ម៉ុក** លោក **កុយ ធួន** និងលោក **សោ ភឹម** មានកន្លែងស្នាក់នៅរបស់ពួកគេផ្ទាល់ខ្លួន។

### ខ.៥. តួនាទីក្នុងក្រសួងការបរទេស បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥

លោក **រ៉ចាម តុន** បាននិយាយថា ក្រសួងការបរទេស (ដែលគាត់បានសំដៅផងដែរថាជា "ប-១") បានចាប់ផ្តើមដំណើរការនៅខែឧសភា ឆ្នាំ១៩៧៥ នៅពេល **អៀង សារី** បានត្រឡប់មកពីបរទេសវិញ ហើយចាប់ពីពេលនោះមក ក្រសួងការបរទេស បានទទួលភ្ញៀវជារៀងរាល់សប្តាហ៍។

លោក **រ៉ចាម តុន** បានផ្តល់សក្ខីកម្មថា គាត់ជាប្រធានអង្គភាពរដ្ឋបាលនៃក្រសួងការទេស។ ហើយគាត់មិនបានបញ្ជាក់ឲ្យច្បាស់ថា តើនណាជាអ្នកចាត់តាំងឲ្យគាត់ធ្វើតួនាទីនេះនោះទេ។ លើសពីនេះទៅទៀត គាត់បាននិយាយថា គាត់ជាមានភារកិច្ចជា "អ្នកគ្រប់គ្រងទាំងនយោបាយ ទាំងសតិអារម្មណ៍ ទាំងចាត់តាំងហ្នឹង គឺគ្រប់គ្រងកម្លាំងហ្នឹង" នៅក្នុងក្រសួងការបរទេស ក៏ដូចជាមើលការខុសត្រូវលើផ្ទះបាយ និងផ្ទះសម្រាប់ភ្ញៀវបរទេសផងដែរ។ ក្រៅពីការងារទាំងនេះ លោក **រ៉ចាម តុន** បាននិយាយថា គាត់នៅតែបន្តរត់សំបុត្រទៅវិញទៅមកក្នុងចំណោម **អៀង សារី** លោក **ខៀវ សំផន** លោក **សុន សេន** និង លោក **ប៉ុល ពត**។ ចំពោះខ្លឹមសារនៃសំបុត្រដែលគាត់បានផ្ញើទៅ គឺគាត់មិនបានដឹងឡើយ។ ហើយមន្ត្រីដទៃទៀត ដែលនៅក្នុងក្រសួងការបរទេសដែលសាក្សីបានរៀបរាប់យ៉ាងច្បាស់នោះ គឺមានលោក **ធួន** ដែលជាអ្នកទទួលខុសត្រូវលើផ្នែកការទូត ហើយនិងលោក **សាឡុត បាន** ហៅ "**សួរ ហុង**"[12] ជាអ្នកទទួលខុសត្រូវកិច្ចការនយោបាយ។ ពួកគេទាំងនោះអស់ រួមបញ្ចូលទាំងសាក្សី ធ្វើសេចក្តីរាយការណ៍ទៅឲ្យលោក **អៀង សារី**។

យោងទៅតាមលោក **រ៉ចាម តុន** ការិយាល័យ ៨៧០ ដំបូងឡើយបានជ្រើសរើសមនុស្សឲ្យទៅធ្វើការនៅក្នុងក្រសួងការបរទេស។ តាមឲ្យដឹងមក **ប៉ង់**[13] ដែលជាអ្នកទទួលខុសត្រូវការិយាល័យ៨៧០ បានផ្តល់គោលការណ៍ណែនាំជាមូលដ្ឋានក្នុងការជ្រើសរើសកម្មករឲ្យធ្វើនៅក្រសួងការបរទេស និងល័ក្ខខ័ណ្ឌជាច្រើននៃការជ្រើសរើស។ សាក្សីបាននិយាយថា បន្ទាប់ពីមានការផ្លាស់ប្តូរមក **ខឿន**[14] បានមកជំនួស **ប៉ង់** ហើយនៅពេលដែល **ខឿន** បានបាត់ខ្លួន លោក **ខៀវ សំផន** បានមកមើលការខុសត្រូវកន្លែងរបស់គាត់ (**ខឿន**)។ នៅពេលដែលមានសំណួរសួរថា តើគាត់បានដឹងអំពីបញ្ហាទាំងនេះដោយរបៀបណានោះ លោក **រ៉ចាម តុន** បានឆ្លើយតបថា៖

> *ខ្ញុំដឹងហ្នឹង របៀបគឺខ្ញុំដឹងពីអ៊ំ **អៀង សារី** ទេប្រាប់ខ្ញុំ។ គាត់ថា "ឥឡូវហ្នឹង **ប៉ង់** គេផ្លាស់ធ្វើការផ្សេងហើយ។ ឥឡូវហ្នឹង **ខឿន** គេអ្នកជំនួស"។ ដល់តែបាត់ **ខឿន** ទៀតទៅគាត់ថា "ឥឡូវនេះមានអ៊ំ **ខៀវ សំផន**" ដែលការងារនេះ គាត់ៗប្រាប់ ដែលខ្ញុំត្រូវទៅទាក់ទងហ្នឹង គឺគាត់ប្រាប់អីចឹង។*

លោក **រ៉ចាម តុន** បានផ្តល់សក្ខីកម្មថា លោក **អៀង សារី** បានបញ្ជាឲ្យគាត់គោរពទៅតាមការណែនាំក្នុងការជ្រើសរើសបុគ្គលិក ដែលបានចែងនៅក្នុងឯកសារចេញដោយការិយាល័យ៨៧០។ គាត់បានបង្ហើបឲ្យដឹងថា នៅដើមឆ្នាំ១៩៧៧ គាត់ខ្លួនឯងផ្ទាល់បានជ្រើសរើសបុគ្គលិកក្រសួងការបរទេស ពីបុរីកីឡា[15] ដោយប្រើប្រាស់ជីវប្រវត្តិសង្ខេប និងត្រួតពិនិត្យទៅលើលក្ខណៈសម្បត្តិនៃការជ្រើសរើស ដោយមិនឲ្យផ្ទុយទៅនឹងការណែនាំពីការិយាល័យ៨៧០។ ចំពោះអ្នកណា ដែលមានសាវតារចេញពីកសិករក្រីក្រ ដោយគ្មានការជាប់

ពាក់ព័ន្ធជាមួយនឹងអតីតក្រុមនៃរបបមុន ត្រូវបានគេពេញចិត្ត។ ទន្ទឹមគ្នានេះដែរ ក្នុងគោលបំណងដើម្បីជ្រើសរើសឲ្យធ្វើការងារនៅក្រៅប្រទេស ការជ្រើសរើស ត្រូវគោរពតាមលក្ខណៈសម្បត្តិជាក់លាក់ ដូចជា "ទាមទារឲ្យមានរូបសម្បត្តិធម្មតា ដូចជា រើសកម្ពស់ មើលទៅរើសតែមនុស្សហ្នឹងសមរម្យ អាចដំណើរការហ្នឹងកើត"។ នៅចុងឆ្នាំ១៩៧៨ មានប្រជាពលរដ្ឋច្រើនជាង ១០០០នាក់ បានកំពុងធ្វើការងារនៅក្រសួងការបរទេស។

### *ខ.៦. វគ្គសិក្សាអប់រំ និងវគ្គទិតៀន*

យោងទៅតាមសាក្សីរូបនេះ មានវគ្គសិក្សាពីរប្រភេទ៖ (ទី១) វគ្គសិក្សាដែលធ្វើឡើងជាទៀងទាត់ និង (ទី២) វគ្គសិក្សាដែលប្រាព្ធធ្វើឡើងជារៀងរាល់បី ឬបួនឆ្នាំម្តង ដោយមានការចូលរួមពីសមាជិកទាំងអស់ពីគណៈមជ្ឈិម និងតំបន់។ គាត់បានបង្ហើបថា បង **ម៉ាន** បានដឹកនាំវគ្គសិក្សាជាលើកដំបូងដែលគាត់បានចូលរួមផងដែរ។ គាត់ក៏បានចូលរួមកិច្ចប្រជុំបីទៅបួនដងផងដែរ ដែលបានដឹកនាំដោយលោក **ប៉ុល ពត** លោក **អៀង សារី** លោកស្រី **អៀង ធីរិទ្ធ** លោក **នួន ជា** និង លោក **ខៀវ សំផន** នៅការិយាល័យដែលពួកគាត់បានឈរជើង។ ជាឧទាហរណ៍ **ប៉ុល ពត** បានធ្វើជាប្រធានក្នុងកិច្ចប្រជុំនៅការិយាល័យ១០០។

ក្នុងអំឡុងពេលកិច្ចប្រជុំទាំងនោះ សាក្សីបាននិយាយថា ពួកគេបានជជែកពិភាក្សាពីស្ថានភាពទូទៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ។ ពួកគេ ត្រូវបានណែនាំឲ្យគោរពតាមគោលការណ៍នៃបដិវត្តន៍ប្រជាធិបតេយ្យជាតិ។ លើសពីនេះទៀត ពួកគេត្រូវបានណែនាំឲ្យស្ទង់កម្រិតនៃការចូលរួមរបស់ប្រជាជន ដែលជាអ្នកបានគាំទ្រចលនាបដិវត្តន៍ និងការរីកចម្រើនក្នុងតំបន់រំដោះ។ គាត់បានបន្ថែមទៀតថា វណ្ណៈកសិករ និងកម្មករ ត្រូវបានចាត់ទុកថា ជាកម្លាំងស្នូលនៃបដិវត្តន៍ ចំណែកឯអ្នកដែលបានប្រឆាំងនឹងបដិវត្តន៍ ត្រូវបានចាត់ទុកជាសត្រូវ។ **វ៉ាចម គុន** បានបន្ថែមទៀតថា ពួកគេត្រូវបានជូនដំណឹងអំពីប្រទេសដែលបានគាំទ្រ និងបានប្រឆាំងនឹងបដិវត្តន៍នេះ ហើយបានបង្រៀនពួកគេថា សត្រូវដ៏សំខាន់ គឺជាពួកចក្រពត្តិនិយមអាមេរិកាំង ទីភ្នាក់ងារ **សេ.អ៊ី.អា** (CIA) និង **កា.ហ្សេ.បេ** (KGB) ។

### *ខ.៧. ការប្រជុំទូទៅ*

នៅពាក់កណ្តាលឆ្នាំ១៩៧១ មានកិច្ចប្រជុំទូទៅមួយ ដែលមានលោក **ប៉ុល ពត** និងលោក **នួន ជា** ជាអធិបតី។ មេដឹកនាំបក្ស និងកម្មាភិបាលមកពីថ្នាក់តំបន់ បានចូលរួមការប្រជុំ លើកលែងតែលោក **អៀង សារី** ដែលនៅក្រៅប្រទេស។ ប្រធានបទដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំនេះ គឺដូចទៅនឹងប្រធានបទនៅក្នុងកិច្ចប្រជុំកន្លងមក។

តាមឲ្យដឹងមក សាក្សីបានចាំថា មានកិច្ចប្រជុំទូទៅផ្សេងទៀត គឺបានរៀបចំឡើងនៅក្នុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៤ នៅក្បែរភូមិអង្គមាស។ លោក **ប៉ុល ពត** លោក **សោ ភឹម** លោក **កុយ ធួន** លោក **តា ម៉ុក** លោក **វន វ៉េន** លោក **សុន សេន** លោក **នួន ជា** លោក **ខៀវ សំផន** និង លោក **អៀង សារី** គឺមានវត្តមាននៅក្នុងការប្រជុំនេះ។ តាមឲ្យដឹងមក លោក **អៀង សារី** បានស្ថិតនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលខ្លីមួយ និងបានចូលរួមកិច្ចប្រជុំនេះ មុននឹងគាត់បានត្រឡប់ទៅប្រទេសចិនវិញ។ ជាគួរឲ្យកត់សម្គាល់នោះ សាក្សីបាន

ចង្អុលបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានវាយរំដោះទីក្រុងភ្នំពេញ និងទូទាំងប្រទេសក្នុងអំឡុងពេលប្រជុំនេះ។

យោងទៅតាមសាក្សី ក្នុងខែឧសភា ឆ្នាំ១៩៧៥ មានការប្រជុំទូទៅមួយទៀត គឺបានធ្វើឡើងនៅព្រះវិហារព្រះកែវមរកតក្នុងរាជធានីភ្នំពេញ។ មេដឹកនាំភូមិភាគមួយចំនួន បានចូលរួមកិច្ចប្រជុំរយៈពេល ១០ថ្ងៃ ដែលបានដឹកនាំដោយ **ប៉ុល ពត** និង **នួន ជា**។ លោក **អៀង សារី** និង **ខៀវ សំផន** ក៏មានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ។ ក្រោយពីការធ្វើបទបង្ហាញស្តីពីស្ថានភាពទូទៅយ៉ាងសង្ខេបរួចមក អ្នកចូលរួមត្រូវបានប្រាប់ថា បដិវត្តន៍ប្រជាធិបតេយ្យ បានទទួលជ័យជម្នះហើយ។ សាក្សីបាននិយាយថា ពួកគេត្រូវបានប្រាប់ថា ពួកគេត្រូវតែរៀបចំខ្លួនដើម្បីធ្វើបដិវត្តន៍សង្គមនិយមតាមរយៈការកសាងប្រទេសជាតិ និងការបង្កើតសហករណ៍ឲ្យរីកចម្រើន ក្នុងគោលបំណងបង្កើតជារដ្ឋកុម្មុយនីស្តមួយ។

### *ខ.៨. ឥរិយាបថ និងភាពគួរជឿជាក់លើសាក្សី*

ក្នុងអំឡុងពេលសួរសំណួរដោយសហព្រះរាជអាជ្ញា សាក្សី **រ៉ចាម តុន** បានបង្ហាញពីមិនអល់អែកក្នុងការឆ្លើយតបនឹងសំណួរ។ គាត់បានបង្ហាញពីការចងចាំដ៏ល្អរបស់គាត់ ដែលអាចចាត់ទុកថា គាត់បានចាំយ៉ាងលម្អិតពីព្រឹត្តិការណ៍ ដែលបានកើតឡើងអស់រយៈពេលជាង៤០ឆ្នាំកន្លងទៅហើយ។ គាត់ក៏មានទំនុកចិត្តក្នុងការផ្តល់ព័ត៌មានជាក់លាក់អំពីរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ប្រតិបត្តិការនៃការិយាល័យសំខាន់ៗ ក៏ដូចជាគោលនយោបាយគន្លឹះនៃបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនផងដែរ ដោយផ្អែកលើសមាជិកភាពរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា និងការចូលរួមរបស់គាត់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផងដែរ។

## ផ្នែកទី ៣៖ បញ្ហាផ្លូវច្បាប់ និងនីតិវិធី

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ បានប្រឈមមុខសាជាថ្មីនឹងបញ្ហានៃការប្រើប្រាស់ឯកសារ ដែលមិនមាននៅក្នុងសំណុំរឿង។ លើសពីនេះ កាលពីសប្តាហ៍មុន អង្គជំនុំជម្រះសាលាដំបូង បានសម្រេចលើការជំទាស់នឹងសំណួរមួយចំនួន ដោយសារតែមិនមានការជាប់ពាក់ព័ន្ធគ្នា (ជាឧទាហរណ៍ ដូចជា ស្ថិតនៅក្រៅវិសាលភាពនៃនីតិវិធី ឬក្រៅជំនាញរបស់សាស្ត្រាចារ្យ **ឆេនដ័ល័រ**) ឬបានទាមទារឲ្យមានចម្លើយសន្និដ្ឋានពីសាក្សី។ អង្គជំនុំជម្រះសាលាដំបូង ក៏បានប្រឈមមុខផងដែរនឹងបញ្ហាដែលទាក់ទងនឹងការធ្វើបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេតនៃសំណុំរឿង។

### ១. ការប្រើប្រាស់ឯកសារដែលមិនបានដាក់បញ្ចូលក្នុងសំណុំរឿង

នៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីថ្ងៃច័ន្ទ មេធាវី **ម៉ៃខល កាណាវ៉ាស** *(Mr. Michael Karnavas)* ដែលជាមេធាវីអន្តរជាតិការពារក្តីឲ្យលោក **អៀង សារី** បានជូនដំណឹងទៅអង្គជំនុំជម្រះថា មេធាវីការពារក្តីឲ្យលោក **អៀង សារី** បានបង្កើតគំនូសតាងមួយដែលបង្ហាញថា សាស្ត្រាចារ្យ **ឆេនដ័ល័រ** បានប្រើប្រាស់ការស្មានផ្សេងៗស្តីពីចំនួនអ្នកស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវី **កាណាវ៉ាស** បានប្រាប់អង្គជំនុំជម្រះថា គំនូសតាងដែលសាស្ត្រាចារ្យ **ឆេនដ័ល័រ** បានសម្អាងក្នុងការបោះពុម្ពផ្សាយរបស់គាត់នោះ មានមួយចំនួន

មិនមានក្នុងសំណុំរឿងនោះទេ។ តាមរយៈលោកស្រីចៅក្រម **ខាតរ៉ាយច៍** *(Judge Silvia CARTWRIGHT)* អង្គជំនុំជម្រះ បានក្រើនរំឭកដល់ភាគីទាំងអស់ថា ឯកសារដែលមិនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ គឺត្រូវទាមទារឲ្យមានការសំណើជាលាយលក្ខណ៍អក្សរ ដោយយោងលើវិធានផ្ទៃក្នុងលេខ៨៧(៤)។[16] យោងតាមការពិចារណាថា វិធានផ្ទៃក្នុងលេខ ៨៧(៤) បានអនុវត្តដើម្បីស្នើសុំឲ្យមានការទទួលយកនូវភស្តុតាងថ្មីណាដែលមិនអាចរកបានក្នុងអំឡុងពេលនៃការបើកការជំនុំជម្រះ មេធាវី **កាណាវ៉ាស** បានតវ៉ាថា គាត់មិនកំពុងណែនាំឲ្យដាក់បញ្ចូលគំនូសតាងនេះទៅជាភស្តុតាងនោះទេ ក៏ប៉ុន្តែគាត់គ្រាន់តែយកមកប្រើប្រាស់ក្នុងការបង្ហាញដំណើរការនៃការសួរសំណួរតែប៉ុណ្ណោះ។ បន្ថែមពីនេះ មេធាវីការពារក្តី បានបកស្រាយថា មានឯកសារចំនួនដប់ដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងគំនូសតាងនោះ ហើយនៅក្នុងនោះមានប្រាំមួយឯកសារមាននៅក្នុងសំណុំរឿង។ ក៏ប៉ុន្តែ លោកប្រធានអង្គជំនុំជម្រះ បានប្រាប់ទៅមេធាវីការពារក្តីថា អង្គជំនុំជម្រះ បានសម្រេចរួចរាល់ហើយលើបញ្ហានេះ ហើយបានណែនាំឲ្យមេធាវីបន្តសំណួរសាក្សីទៅតាមនីតិវិធី។

កាលពីថ្ងៃអង្គារ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** គឺលោក **អេនឌ្រូ អ៊ីនូហ្ស៊ី** *(Mr. Andrew IANUZZI)* បានស្នើឲ្យមានការទទួលយកឯកសារថ្មី ឬក៏មានជម្រើសផ្សេងៗពីនេះ ដើម្បីស្វែងរកការបកស្រាយទាក់ទងទៅនឹងការប្រើប្រាស់ឯកសារថ្មី។ លោក **អ៊ីនូហ្ស៊ី** បានថ្លែងថា មេធាវីការពារក្តីឲ្យលោក **នួន ជា** គឺមានអត្ថបទមួយដែលមាន១១ទំព័រ បានមកពី "កាសែតញូវយ៉កប៊ុស្ក៍ *(New York Review of Books)*" ដែលទើបតែបានចុះផ្សាយនៅថ្ងៃមុននោះ។ មេធាវីការពារក្តី បានបញ្ជាក់យ៉ាងច្បាស់ថា វាមានផ្ទុកនូវព័ត៌មានដែលមេធាវីការពារក្តីឲ្យលោក **នួន ជា** បានមានបំណងចង់ដាក់បង្ហាញនៅចំពោះមុខសាក្សីជំនាញ **ដេវីដ ឆេនដ៍ល័រ** *(Mr. David Chandler)*។ មេធាវី **អ៊ីនូហ្ស៊ី** បានស្នើសុំឲ្យមានការអនុញ្ញាតក្នុងការចែកចាយអត្ថបទចតចម្លងនេះ ដើម្បីឲ្យភាគីទាំងអស់ធ្វើការឆ្លើយតបនៅព្រឹកស្អែក ហើយបន្ទាប់មក អង្គជំនុំជម្រះអាចសម្រេចថា តើមេធាវីការពារក្តីឲ្យលោក **នួន ជា** ត្រូវបានអនុញ្ញាតឲ្យដាក់អត្ថបទនៅចំពោះមុខសាស្ត្រាចារ្យ **ឆេនដ៍ល័រ** ដែរឬក៏អត់។ ដោយតំណាងឲ្យអង្គជំនុំជម្រះ លោកស្រីចៅក្រម **ខាតរ៉ាយច៍** បានថ្លែងដូចតទៅថាៈ

> *សំណើត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ អនុលោមទៅតាមវិធាន៨៧(៤)[17] ហើយយ៉ាងហោចណាស់គឺថា មូលហេតុដែលយើងបញ្ជាក់នោះ គឺថាអត្ថបទសារព័ត៌មានដែលទាក់ទងហ្នឹង មានតែភាសាមួយទេ ហើយមិនអាចឲ្យធ្វើសេចក្តីសម្រេចបានទេ រហូតទាល់តែឯកសារវែងនេះ ត្រូវបានបកប្រែទៅជាភាសាខ្មែរយ៉ាងហោចណាស់។ ដូច្នេះ ដើម្បីឲ្យអង្គជំនុំជម្រះអាចពិភាក្សា ហើយអាចឈានដល់សេចក្តីសម្រេចបាន។*

មេធាវីការពារក្តីបានដាក់សំណើថា គាត់បានអាននូវអត្ថបទខ្លីៗ ដែលគាត់ចង់ឲ្យសាក្សីផ្តល់ជាមតិយោបល់ ហើយនិងត្រូវមានការបកប្រែដែលអាចធ្វើទៅបាននៅបន្ទាប់ពីនោះ។ ក៏ប៉ុន្តែ លោកប្រធាន **និល ណុន** បានកាត់សម្តីដោយនិយាយថា អង្គជំនុំជម្រះ បានសម្រេចរួចហើយលើបញ្ហានេះ ហើយបានណែនាំមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** បន្តសំណួរទៅកាន់សាក្សីជំនាញ។

## ២. សំណួរដែលមិនជាប់ពាក់ព័ន្ធ និងក្រៅវិសាលភាពនៃជំនាញរបស់សាក្សី

អង្គជំនុំជម្រះ បានណែនាំភាគីទាំងអស់ឲ្យរក្សាការតាំងសំណួររបស់ខ្លួននៅក្នុងកម្រិតនៃការបែងចែកសវនាការ ហើយជាពិសេស នៅពេលដែលមេធាវីការពារក្ដីឲ្យលោក **នួន ជា** បានមានបំណងទាមទារឲ្យសាស្ត្រាចារ្យ**ឆេនង័ល័រ** ផ្ដល់ជាយោបល់របស់គាត់លើបញ្ហាថា តើការកាត់ក្ដីមេដឹកនាំខ្មែរក្រហម អាចជាភាពអាម៉ាសដល់រដ្ឋាភិបាល ឬក៏ថាតើវាជាការគួរឲ្យភ្ញាក់ផ្អើលដែរឬទេ ដែលមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា មិនបានអើពើទៅនឹងការកោះហៅដើម្បីផ្ដល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក។ អង្គជំនុំជម្រះ បានណែនាំសាស្ត្រាចារ្យ **ឆេនង័ល័រ** មិនឲ្យឆ្លើយតប ហើយលោកប្រធាន **និល ណុន** បានធ្វើការរំលឹកមេធាវីអន្តរជាតិការពារក្ដីគឺលោក **ហ្សាស្ពើ ប៉ៅ** *(Mr. Jasper PAUW)* ថាគាត់គួរតែដាក់សំណើនៅក្នុងសេចក្ដីសន្និដ្ឋានរបស់គាត់ជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធានផ្ទៃក្នុងលេខ៩២។ លោកស្រីចៅក្រម **ខាតរ៉ាយច៍** បានបន្ថែមទៀតថា លោក **ប៉ៅ** អាចសួរសាក្សីលើបញ្ហាណាដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង០០២ ដំណាក់កាលទី១។

## ៣. ការអះអាងលើសេចក្ដីថ្លែងការណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត

ដោយមានការប្រកាសពីការបង្ហាញខ្លួនរបស់លោក **រ៉ចាម តុន** នៅចំពោះមុខអង្គជំនុំជម្រះ មេធាវី **កាណាវ៉ាស** បានបង្ហាញអំពីការព្រួយបារម្ភលើភាពមិនប្រក្រតីនៃសេចក្ដីថ្លែងការណ៍របស់លោក **រ៉ចាម តុន** ដែលផ្ដល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត។ មេធាវីការពារក្ដីបានពន្យល់ថា មេធាវីការពារក្ដីឲ្យលោក **អៀង សារី** បានស្ដាប់ការថតចម្លងជាសំឡេងនៃបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយនឹងលោក **រ៉ចាម តុន** ហើយតាមយោបល់របស់គាត់ អ្វីដែលច្បាស់នោះ "គឺមិនមែនជាការសន្ទនាទេ" ពីព្រោះវាមិនមែនជាការឆ្លើយសំណួរតាមចិត្តគាត់នោះទេ សាក្សីហាក់បីដូចជាបានអាននូវចម្លើយរបស់គាត់ក្នុងការឆ្លើយទៅនឹងសំណួរដែលបានសួរក្នុងកិច្ចសម្ភាសន៍។

ដើម្បីដោះស្រាយបញ្ហានេះ អង្គជំនុំជម្រះបានស្នើលោក **រ៉ចាម តុន** ឲ្យបកស្រាយពីរបៀបដែលកិច្ចសម្ភាសន៍ទាំងពីរលើករបស់គាត់ បានធ្វើឡើងជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត។ យោងទៅតាមលោក **រ៉ចាម តុន** "គាត់លើកសំណើទៅ ខ្ញុំឆ្លើយ។ ខ្ញុំឆ្លើយសំណួររបស់គាត់ហ្នឹងទៅ។ អ្នកដែលស៊ើបអង្កេតហ្នឹង គាត់លើកឡើងសំណួរហ្នឹងទៅ ស្អីដែលខ្ញុំដឹង ខ្ញុំឆ្លើយតាមហ្នឹងទៅ។" គាត់បានអះអាងបន្ថែមទៀតថា ការិយាល័យសហចៅក្រមស៊ើបអង្កេត បានផ្ដល់ឲ្យគាត់នៅការថតចម្លងនៃកិច្ចសម្ភាសន៍របស់គាត់ ហើយថា "ឃើញដូចគ្នាទាំងពីរលើកនោះ មើលទៅដូចគ្នាទេ លើកទីមួយ លើកទីពីរ ដូចគ្នា អត់មានអីប្លែកទេ"។ ដោយយល់ឃើញថាគ្មានភាពមិនប្រក្រតីបានកើតឡើង លោកប្រធានអង្គជំនុំជម្រះ ក៏បានណែនាំឲ្យសហព្រះរាជអាជ្ញាបន្តសំណួរសួរទៅកាន់សាក្សី។

## ៤. សំណើពាក់ព័ន្ធទៅនឹងការចូលរួមរបស់ជនជាប់ចោទក្នុងកិច្ចដំណើរការនីតិវិធី

មុនពេលឈប់សម្រាកថ្ងៃត្រង់ មេធាវី **អ៊ីនូហ្ស៊ី** បានស្នើអង្គជំនុំជម្រះឲ្យអនុញ្ញាតឲ្យកូនក្តីរបស់គាត់ចូលរួមតាមដានសវនាការពីបន្ទប់ឃុំឃាំងនៅខាងក្រោមសាលសវនាការ ដោយសារយោងទៅលើបញ្ហាសុខភាពរបស់ជនជាប់ចោទ។ ក្នុងសំណើនោះ លោក **អ៊ីនូហ្ស៊ី** បាន ថ្លែងដូចតទៅថា៖

> *ខ្ញុំទទួលស្គាល់ថា តុលាការមានភារកិច្ចក្នុងការរក្សាវត្តមាន។ ខ្ញុំសូមបញ្ជាក់ឲ្យបានត្រឹមត្រូវនៅក្នុងប្រតិចារឹក ហើយខ្ញុំសូមបញ្ជាក់ថា គាត់មិនដែលមានការផ្ទង់អារម្មណ៍បានពេញលេញនៅក្នុងសវនាការនេះទេ ដោយសារតែបញ្ហានេះឯង។*

នៅពេលភ្លាមនោះ លោកប្រធាន **និល ណុន** បានសម្រេចគាំទ្រសំណើរបស់លោក **អ៊ីនូហ្ស៊ី** ហើយលោកប្រធានក៏បានបញ្ជាក់ផងដែរថា នឹងមានការផ្តត់ផ្គង់ឲ្យបានគ្រប់គ្រាន់ក្នុងបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការដើម្បីអនុញ្ញាតឲ្យជនជាប់ចោទអាចតាមដានកិច្ចដំណើរការនីតិវិធីបាន និង អាចធ្វើការទំនាក់ទំនងជាមួយនឹងមេធាវីការពារក្តីរបស់ខ្លួនបាន។ បន្ថែមពីនេះទៀត មេធាវីការពារក្តីទាំងអស់បានត្រួតពិនិត្យបន្ទប់ឃុំឃាំងនោះ ហើយមិនមានការជំទាស់អ្វីឡើយ ទាក់ទៅនឹងឧបករណ៍ដែលបានបំពាក់នៅក្នុងបន្ទប់ឃុំឃាំងនោះ។ លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយច៍** បានប្រាប់ភាគីទាំងអស់ថា ប្រសិនជាមានការសម្របសម្រួលណាមួយ ដែលមិនបានបំពេញតាមគោលបំណងរបស់មេធាវីការពារក្តីចង់បាននោះទេ វាគឺជាភារកិច្ចរបស់មេធាវីក្នុងការលើកឡើងនូវបញ្ហាទាំងនោះទៅកាន់អង្គជំនុំជម្រះ ជាជាងផ្តល់យោបល់ទូទៅក្នុងតុលាការ។

មេធាវី **អ៊ីនូហ្ស៊ី** បានបកស្រាយថា គាត់មិនបានរិះគន់ពីការសម្របសម្រួលស្អីទេ ហើយអ្វីដែលគាត់ចង់បញ្ជាក់គឺថា កូនក្តីរបស់គាត់មិនអាចចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការបានឡើយ ដោយសារតែបញ្ហាសុខភាព។ លោកស្រីចៅក្រមបានឆ្លើយតបដូចខាងក្រោម៖

> *ដូច្នេះ អង្គជំនុំជម្រះច្បាស់ហើយ គឺថាលោកចង់ដាក់ការទទួលខុសត្រូវដោយមិនច្បាស់លាស់ដល់តុលាការ ឬអង្គជំនុំជម្រះខ្លួនឯង។ ប៉ុន្តែការទទួលខុសត្រូវជារបស់លោកក្នុងការជម្រាបទៅកូនក្តីរបស់លោក ឬក៏ជាមួយកូនក្តីរបស់លោកថា គាត់មិនអាច ឬក៏អាចតាមដានដោយមានប្រសិទ្ធភាព ដោយសកម្ម ឬដូចម្តេច។*

# ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

កិច្ចដំណើរការនីតិវិធីសវនាការនាសប្តាហ៍នេះ គឺជាការកត់សម្គាល់ពីមានការលំបាកក្នុងការបកប្រែភាសា ដែលភាគច្រើនបណ្តាលមកពីការឆ្លើយឆ្លងគ្នាយ៉ាងលឿន ពេករវាងមេធាវីការពារក្តី និងសាស្ត្រាចារ្យ **ដេវីដ ឆេនដ័ល័រ** ។ បន្ថែមពីនេះ លោកប្រធាន **និល ណុន** បានបន្តយ៉ាងយកចិត្តទុកដាក់លើការប្រើប្រាស់ពេលវេលាដែលបានបែងចែកទៅឲ្យមេធាវីការពារក្តីសម្រាប់សួរសំណួរ និងបានកាត់សម្តីនៅពេលណាដែលមានសំណួរទំនងជាច្រំដែល ឬមិនពាក់ព័ន្ធ។

## ក. វត្តមាន

នាសប្តាហ៍នេះ ជនជាប់ចោទ **អៀង សារី** បានបន្តចូលរួមសវនាការពីបន្ទប់ឃុំឃាំងក្រោមសាលសវនាការ។ ជនជាប់ចោទ **នួន ជា** ក៏បានជួបប្រទះការលំបាកលើបញ្ហាសុខភាព ហើយបានបោះបង់សិទ្ធិរបស់គាត់នៅក្នុងការចូលរួមសវនាការដោយផ្ទាល់ លើគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់នៅពេលរសៀល។ ជនជាប់ចោទ **ខៀវ សំផន** បានចូលរួមកិច្ចដំណើរការនីតិវិធីសវនាការក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍ លើកលែងតែនៅវគ្គទី៤នៃកិច្ចពិភាក្សាដេញដោលក្តី កាលពីថ្ងៃព្រហស្បតិ៍ នៅពេលដែលតែគាត់បានចូលរួមសវនាការពីបន្ទប់ឃុំឃាំងក្រោមសាលសវនាការ ដោយសារតែអាការៈក្អករបស់គាត់។

**វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖** ដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ២០ ទៅ ៣០នាក់ បានចូលរួមតាមដានសវនាការក្នុងសាលសវនាការ និងសាលសាធារណជន។

**វត្តមានសាធារណជន៖** សាធារណជន បានមានវត្តមានចូលរួមតាមដានសវនាការនេះយ៉ាងល្អពេញមួយសប្តាហ៍។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ប្រមាណជា ៤០នាក់ បានចូលរួមស្តាប់សវនាការក្នុងរយៈពេលបួនថ្ងៃ។ កាលពីថ្ងៃច័ន្ទ មានប្រជាជនប្រហែលជា ៣០០នាក់ មកពីខេត្តតាកែវ និងនិស្សិតចំនួន ១០០នាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (តាមរយៈកិច្ចប្រឹងប្រែងនៃកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន) ហើយយ៉ាងហោចណាស់មាននិស្សិតនិស្សិតវិទ្យាល័យចំនួន ៣០នាក់ មកពីសហរដ្ឋអាមេរិច បានចូលរួមតាមដានស្តាប់សវនាការ។ នៅថ្ងៃអង្គារពេលព្រឹក យ៉ាងយោចណាស់ មានប្រជាជនចំនួន ៣០០នាក់ មកពីភូមិប្រាំមា និងឃ្លាំងស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមបានចូលរួម។ នៅថ្ងៃពុធ ប្រជាជនច្រើនជាង ៤០០នាក់ មកពីស្រុកបារិត ខេត្តស្វាយរៀង បានមានវត្តមានតាមដានសវនាការ។ នៅថ្ងៃចុងក្រោយ ថ្ងៃព្រហស្បតិ៍ ប្រជាជនចំនួន ៣០០នាក់ មកពីស្រុស្រីសន្ធរ ខេត្តកំពង់ចាម បានចូលរួមស្តាប់សវនាការរហូតដល់ថ្ងៃត្រង់។ នៅពេលរសៀល មានសិស្សានុសិស្សចំនួន ២០០នាក់ មកពី វិទ្យាល័យជ័យវរ្ម័ទី៧ ខេត្តកណ្តាល បានចូលរួមតាមដាននៅក្នុងសាលសាធារណជន។

## ខ. ឥរិយាបទក្នុងសាលសវនាការ

ក្នុងអំឡុងពេលនៃការសាកសួរដេញដោលលោកសាស្ត្រាចារ្យ **ដេវីដ ឆេនដ័ល័រ** ពីសំណាក់មេធាវី **កាណាវ៉ាស** មានការទាស់ទែងគ្នារវាងសាក្សី និងមេធាវីការពារក្តី បានកើតឡើង ហើយបណ្តាលឲ្យសាស្ត្រាចារ្យ **ឆេនដ័ល័រ** និយាយថា "ខ្ញុំមិនប្រកួតប្រជែងជាមួយលោកទេ" ហើយ "ខ្ញុំមិនមែនចង់មើលទៅមានលក្ខណៈដូចការពារខ្លួន ឬបំពានខ្លាំងទេ"។ នៅត្រង់ចំណុចនេះ មេធាវី**កាណាវ៉ាស** បានកត់សម្គាល់ឃើញថាសាស្ត្រាចារ្យ **ឆេនដ័ល័រ** មើលទៅ "ហាក់បីដូចជាបំពាន ហើយការពារខ្លួន"។ ប្រការបែបនេះ បានធ្វើឲ្យលោកស្រីចៅក្រម **ខាតរ៉ាយថ៍** ក្នុងនាមអង្គជំនុំជម្រះបានចូលធ្វើអន្តរាគមន៍៖

*លោក **កាណាវ៉ាស** វិធីដែលលោកសួរសំណួរនេះ យើងយល់ឃើញថា ដូចជាលោកធ្វើសេចក្តីសន្និដ្ឋាន ដូចជាជំរុញឲ្យអ្នកជំនាញឆ្លើយឲ្យដូចដែលលោកចង់បាន ឲ្យរឹងមាំ។*

*ដូច្នេះសូមលោកកុំចោទប្រកាន់ទៅសាក្សី ឬក៏អ្នកជំនាញ គឺថាកុំឲ្យប្រើពាក្យថាគាត់ជាមនុស្សគឃ្លើន ដែលថាបំពានក្នុងគំនិតណាមួយនោះ។*

### គ. បញ្ហាបកប្រែភាសារ និងបច្ចេកទេស

នៅសប្ដាហ៍នេះ បញ្ហាបកប្រែបានកើតឡើងនៅពេលដែលក្រុមមេធាវីការពារក្ដី បានកំពុងសួរសំណួរលោកសាស្ត្រាចារ្យ **ដេវីដ ឆេនដ៍ល័រ** ជាពិសេសនោះ គឺនៅពេលដែលមេធាវី **កាណាវ៉ាស** បានសួរសំណួរលើសាក្សីជំនាញ។ មានពេលខ្លះ ការឆ្លើយឆ្លងសំណួរ និងចម្លើយរវាងមេធាវី **កាណាវ៉ាស** និងសាស្ត្រាចារ្យ **ឆេនដ៍ល័រ** គឺលឿនពេកសម្រាប់អ្នកបកប្រែចាប់មិនបាន ភ្លាមៗនោះ អង្គជំនុំជម្រះបានរំលឹកភាគីឲ្យឈប់ និងបន្ថយល្បឿន។ មុននឹងបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃអង្គារ គឺនៅក្រោយពេលដែលមានការភាន់ច្រឡំមួយបានកើតឡើងទាក់ទងនឹងការបកប្រែជាភាសាខ្មែរ រវាងពាក្យ "គណៈអចិន្ត្រៃយ៍" និង "គណៈមជ្ឈិម" លោកប្រធាន **និល ណុន** ក៏បានប្រាប់អ្នកបកប្រែ "ឲ្យមានការប្រុងប្រយ័ត្ន"។

### ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | ការសម្រាក ពេលព្រឹក | អាហារ ថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោង សរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ២៣/០៧/១២ | ៩:០០ | ១០:៣៣-១០:៥៣ | ១២:១២-១៣:៣២ | ១៤:១៩-១៤:៤១ | ១៦:១៦ | ៥ម៉ោង និង ១៤នាទី |
| ថ្ងៃអង្គារ ២៤/០៧/១២ | ៩:០៥ | ១០:៣៧-១១:០២ | ១២:០០-១៣:៣១ | ១៤:៤២-១៥:០២ | ១៦:០០ | ៤ម៉ោង និង ៣៩នាទី |
| ថ្ងៃពុធ ២៥/០៧/១២ | ៩:០២ | ១០:៤២-១១:០១ | ១១:២៧-១៣:៣១ | ១៤:៤៣-១៥:០០ | ១៦:០២ | ៤ម៉ោង និង ២០នាទី |
| ថ្ងៃព្រហស្បតិ៍ ២៦/០៧/១២ | ៩:០១ | ១០:៣២-១០:៥៣ | ១២:០៣-១៣:៣៩ | ១៤:៤៣-១៥:០០ | ១៦:០១ | ៤ម៉ោង និង ៤៦នាទី |
| ***ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ៖*** | | | | *៤ម៉ោង និង៤៤នាទី* | | |
| ***ចំនួនម៉ោងសរុបក្នុងសប្ដាហ៍នេះ៖*** | | | | *១៨ម៉ោង និង៥៩នាទី* | | |
| ***ចំនួនសរុបនៃ ម៉ោង ថ្ងៃ និង សប្ដាហ៍៖*** | | | | *៣៦៦ម៉ោង និង៥នាទី* | | |
| ***រយៈពេលសវនាការចំនួន ៨៤ថ្ងៃ អំឡុងពេល ២៥សប្ដាហ៍*** | | | | | | |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center,University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to theestablishment of justice initiatives and capacity-building programs in the human rights sector in South-East Asia.The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the BritishEmbassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes,PavithraPrakash Nair, Noyel Ry, Juan Pablo Stein, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoringand Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at<www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] The Witness confirmed that Pol Pot was known by the monickers "Brother Number One," and "UncleSecretary," and his party alias "870."

[2] See CASE 002 KRT TRIAL MONITOR. Issue No. 2, Fitness to Stand Trial I (29-31 August 2011); and CASE 002KRT TRIAL MONITOR. Issue No. 4, Fitness to Stand Trial II (19-20 October 2011).

[3] "Perhaps a hundred thousand men and women, and probably more, were executed without trial. In rural areas, most of the killings occurred when young cadre enforced what they understood to be the will of the organization. Some of these executions, perhaps most, were impulsive overreactions." David Chandler, Brother Number One: A Political Biography of Pol Pot, Boulder: Westview Press (1999), 160.

[4] AIJI KRT Trial Monitor reports on Case 001 are available at <http://krtmonitor.org/category/case-001-reports/>.

[5] Accused NuonChea asked the following questions: 1) "First question is; from the very beginning, until now,the conflicts between Cambodian people and -- the People's Party of Cambodia and Vietnam -- what has beenthe cause of these disputes? Has it been resulted from the border dispute or from other matters?" and 2) "Whatwas the cause of the birth of the Communist Party of Kampuchea?"

[6] See NuonChea's testimony on the history of the CPK in Case 002 KRT Trial Monitor. Issue No. 8, Hearing onEvidene Week 3 (10-12 January 2012).

[7] See KhieuSamphan's response to the Opening Statement of the Prosecution in Case 002 KRT Trial Monitor.Issue No. 5, Opening Statement (21-23 November 2011).

[8] Authorzed by John Carey.

[9] Stephen Heder with Brian D. Tittemore, Seven Candidates for Prosecution: Accountability for the Crimes of theKhmer Rouge, War Crimes Research Office, American University (July 2001).

[10] See CASE 002 KRT TRIAL MONITOR. Issue No. 20, Hearing on Evidence Week 15 (23-26 April 2012); and CASE002 KRT TRIAL MONITOR. Issue No. 21, Hearing on Evidence Week 16 (30 April, 2-3 May 2012).

[11] Among the mobile offices Rochoem Ton cited as examples were S24, S22, S35, S74, B17, B19, B20.

[12] Saloth Ban testified before the Trial Chamber from 23 April to 3 May 2012. See CASE 002 KRT TRIALMONITOR. Issue No. 20, Hearing on Evidence Week 15 (23-26 April); and CASE 002 KRT TRIAL MONITOR. Issue No.21, Hearing on Evidence Week 16 (30 April, 2-3 May 2012).

[13] According to Duch, Chhim Sam Aok alias "Comrade Pang" was responsible for the "Government Office".See CASE 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012). 3. During his testimony, Witness Saloth Ban stated that Pang disappeared shortly before the Vietnamese arrived in January1979. See CASE 002 KRT TRIAL MONITOR. Issue No. 20, Hearing on Evidence Week 15, (23-26 April 2012). 3.

[14] SeuaVasi alias "Comrade Doeun" was Chairman of Political Office 870. Doeun later chaired the CommerceCommittee. See CASE 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012).3; and CASE 002 KRT TRIAL MONITOR. Issue No. 24, Hearing on Evidence Week 19 (28-31 May 2012). 10.

[15] The Closing Order describes BoreiKeila as a meeting place, also referred to as K-6. At BoreiKeila, NuonChea was said to have conducted several mass political trainings where he taught the policies of the CPK toParty cadres and workers in Phnom Penh. OCIJ. "Closing Order" (15 September 2010). D427. Paragraphs 59and 886.

[16] "During the trial, either on its own initiative or at the request of a party, the Chamber may summon or hear any person as a witness or admit any new evidence which it deems conducive to ascertaining the truth. Any partymaking such request shall do so by a reasoned submission. The Chamber will determine the merit of any suchrequest in accordance with the criteria set out in Rule 87(3) above. The requesting party must also satisfy theChamber that the requested testimony or evidence was not available before the opening of the trial.Extraordinary Chambers in the Courts of Cambodia Internal Rules (Rev. 8), as revised on 3 August 2011. Rule87(4).

[17] Ibid.

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

This publication was originally produced pursuant to a project supported by the War Crimes Studies Center (WCSC), which was founded at the University of California, Berkeley in 2000. In 2014, the WCSC re-located to Stanford University and adopted a new name: the WSD Handa Center for Human Rights and International Justice. The Handa Center succeeds and carries on all the work of the WCSC, including all trial monitoring programs, as well as partnerships such as the Asian International Justice Initiative (AIJI).

A complete archive of trial monitoring reports is available online at:

http://handacenter.stanford.edu/reports-list

For more information about Handa Center programs, please visit:

http://handacenter.stanford.edu